# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 17-Jan-2013, 15:56
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ : សាធារណៈ/Public
ប្រភេទនៃចំណាត់ថ្នាក់ឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

## សារណារបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ស្តីពីច្បាប់ខ្មែរក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀត ពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំ

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ចម្លងជូន៖ |
|---|---|---|
| **សហព្រះរាជអាជ្ញា៖** | **អង្គជំនុំជម្រះសាលាដំបូង៖** | **ជនជាប់ចោទ៖** |
| ជា លាង | ចៅក្រម **និល ណុន** ជាប្រធាន | នួន ជា |
| Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម **យ៉ា សុខន** | ខៀវ សំផន |
| | ចៅក្រមJean-Marc LAVERGNE | **មេធាវីការពារក្តី៖** |
| | ចៅក្រម **យូរ ឧត្តរា** | |

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU FORT

សុន អរុណ

Michiel PESTMAN

Victor KOPPE

អាង ឧត្តម

Michael G. KARNAVAS

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

Jacques VERGÈS

## I. សេចក្តីផ្តើម

1. អនុលោមតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាដាក់សារណាបន្ទាប់នេះស្តីពីច្បាប់ជាធរមានពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ("អំពើអមនុស្សធម៌ផ្សេងៗទៀត")[1]។ នៅក្នុងសំណុំរឿង០០២/០១ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (អំពើអមនុស្សធម៌ផ្សេងៗទៀត) ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនមួយផ្នែកដោយបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងការដាក់សារណានេះ សហព្រះរាជអាជ្ញាលើកឡើងដោយសង្ខេបនូវធាតុផ្សំនៃការជម្លៀសដោយបង្ខំ និងកាលៈទេសៈត្រូវបំផុតដែលការផ្លាស់ទីកន្លែងប្រជាជនដោយបង្ខំ ត្រូវបានអនុញ្ញាតឲ្យធ្វើតាមច្បាប់អន្តរជាតិ។

2. សារណានេះគឺផ្តោតទៅលើការវិវត្តន៍នៅក្នុងច្បាប់ស្តីពីការជម្លៀសដោយបង្ខំ មកត្រឹមពេលមានការជម្លៀសក្នុងដំណាក់កាលទី១ និងទី២។ ទោះបីសារណានេះពិភាក្សាពីការវិវត្តន៍ផ្នែកច្បាប់ដែលកើតក្រោយអំឡុងពេលនោះក៏ដោយ ក៏ការវិវត្តន៍ទាំងនេះបានលើកឡើងនៅក្នុងបរិបទ ឬត្រូវបានពិភាក្សាជាធម្មតាជាងសម្រាប់តម្លៃនៃការបកស្រាយ និងជាពន្លឺដែលអាចអនុវត្តបាន ដែលការវិវត្តន៍ទាំងនោះផ្តល់នូវទស្សនាទានដែលមានអត្ថិភាពរួចហើយមុនឆ្នាំ១៩៧៥[2]។

---

[1] **E163/5** កាលបរិច្ឆេទដាក់សេចក្តីសន្និដ្ឋានចំពោះផ្នែកច្បាប់ធរមាននៃសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោល ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២។ កាលបរិច្ឆេទដាក់ឯកសារ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២ ត្រូវបានពន្យារពេលជាបន្តបន្ទាប់រហូតដល់ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ តាមរយៈសារទំនាក់ទំនងពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ជូនដល់ភាគី ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ "។

[2] អង្គជំនុំជម្រះតុលាការកំពូលបានរំឭកថា ការវិភាគដោយយកចិត្តទុកដាក់លើយុត្តិសាស្ត្រតុលាការ *មិនអចិន្ត្រៃយ៍* គឺជាការចាំបាច់ដើម្បីធានាឲ្យមានការគោរពគោលការណ៍នីត្យានុកូលភាព ប៉ុន្តែមិនត្រូវបដិសេធការអនុវត្តយុត្តិសាស្ត្រនេះទាំងមូលទេ។ សូមមើល សាលដីកា សំណុំរឿង ០០១ ឯកសារ F28, ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ៩៥ ដល់ ៩៧។ ដោយផ្អែកលើគោលការណ៍ទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលបានឯកភាពលើការប្រើប្រាស់យុត្តិសាស្ត្រ *មិនអចិន្ត្រៃយ៍* ដែល "មានមូលដ្ឋានមួយផ្នែកនៅក្នុងយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី II ដែលទាមទារឲ្យអង្គជំនុំជម្រះតុលាការកំពូលងាកទៅរកយុត្តិសាស្ត្រនេះដើម្បីបញ្ជាក់អំពីភស្តុតាងយ៉ាងសំខាន់នៃស្ថានភាពច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលពាក់ព័ន្ធនោះ [សំណុំរឿង ០០១]"។ *ដូចខាងលើ,* កថាខណ្ឌ ១៤៦; *សូមមើលផងដែរ* កថាខណ្ឌ ២៨០ (អនុញ្ញាតឲ្យប្រើប្រាស់យុត្តិសាស្ត្រនៃតុលាការមិនអចិន្ត្រៃយ៍ ដែល

## II. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត និងការជម្លៀសដោយបង្ខំ

3. ដូចដែលអង្គបុរេជំនុំជម្រះបានកត់សម្គាល់រួចមកហើយគឺថា "អំពើអមនុស្សធម៌ផ្សេងៗទៀត *បទល្មើសនោះ* គឺជាបទល្មើសមួយរួចទៅហើយតាមច្បាប់អន្តរជាតិ"[3]។ ហេតុនេះ តាមគោលការណ៍នីត្យានុកូល សហព្រះរាជអាជ្ញាពុំចាំបាច់បង្ហាញថា ឧក្រិដ្ឋកម្មដែលមានលក្ខណៈ "ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ជាអំពើអមនុស្សធម៌ផ្សេងទៀត ដែលឧក្រិដ្ឋកម្មនីមួយៗត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិខុសគ្នាឡើយ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ ៩៧៩"[4]។ ដូចដែលអង្គបុរេជំនុំជម្រះបានពន្យល់រួចមកហើយថា៖ "ការដែលតម្រូវថាប្រភេទរងនីមួយៗនៃអំពើអមនុស្សធម៌ផ្សេងៗទៀត បង្ហាញពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលតាមច្បាប់អន្តរជាតិ គឺជាការធ្វើឱ្យប្រភេទនៃអំពើអមនុស្សធម៌ផ្សេងៗទៀតនោះ ពុំមានអត្ថន័យ"[5]។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា "លក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋតូបនីយកម្ម ត្រូវតែភ្ជាប់ទៅនឹងប្រភេទនៃអំពើអមនុស្សធម៌ផ្សេងៗទៀតមួយប៉ុណ្ណោះ ហើយមិនមែនជាអំពើស្នូលដែលបង្កើតបានជាអំពើអមនុស្សធម៌ផ្សេងៗទៀតនោះឡើយ"[6]។ អំពើអមនុស្សធម៌ផ្សេងៗទៀតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅចំពោះមុខយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ត្រូវបានកំណត់ដោយអង្គបុរេជំនុំជម្រះរួចហើយ[7]។

---

ធាតុផ្សំនៃនិយមន័យនៃឧក្រិដ្ឋកម្មមួយ "ត្រូវសន្និដ្ឋានពីអង្គហេតុ និងសំអាងហេតុរបស់តុលាការក្រោយសង្គ្រាមលោកលើកទី II ដែលជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលនៅជាធរមានក្នុងប្រទេសកម្ពុជា ឆ្នាំ ១៩៧៥")។

[3] សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ឯកសារ D427/2/15, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១, កថាខណ្ឌ ១៥៦ (ការបញ្ជាក់បន្ថែមនៅក្នុងឯកសារដើម) (ដោយធ្វើការដកស្រង់រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Blagojević និង Jokić*, សំណុំរឿង IT-02-60-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង I របស់ ICTY), ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥, កថាខណ្ឌ ៦២៤)។

[4] *ដូចខាងលើ,* កថាខណ្ឌ ១៥៦។

[5] *ដូចខាងលើ,* កថាខណ្ឌ ១៥៦។

[6] *ដូចខាងលើ,* កថាខណ្ឌ ១៥៦។

[7] *ដូចខាងលើ,* កថាខណ្ឌ ១៥៧, កថាខណ្ឌ ១៥៩ ដល់ ១៦៥។

4. អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ពីច្បាប់នៃអំពើអមនុស្សធម៌ផ្សេងៗទៀត នៅក្នុងសាលក្រមរបស់ខ្លួនក្នុងសំណុំរឿង០០១ ថា៖

*អំពើអមនុស្សធម៌ផ្សេងៗទៀតរួមមានបទល្មើស ដែលនៅសេសសល់ផ្សេងៗទៀត ដែលមានបំណងចាត់ទុកអំពើនោះថាជាបទល្មើស នៅពេលដែលអំពើនោះបំពេញលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែមិនបានបំពេញលក្ខខណ្ឌតម្រូវនៃបទល្មើសមួយក្នុងចំណោមបទល្មើសជាក់លាក់ផ្សេងៗទៀតឡើយ។ អំពីសកម្ម ឬអកម្ម ត្រូវតែមាន "ស្ថានទម្ងន់ស្រដៀងគ្នាគ្រប់គ្រាន់ទៅនឹងបទល្មើសជាក់លាក់ផ្សេងៗទៀត" ដើម្បីបង្កើតបានជាអំពើអមនុស្សធម៌។ ឋានៈទំនៀមទម្លាប់នៃឧក្រិដ្ឋកម្មនេះក៏មានចែងយ៉ាងច្បាស់ដែរ។ ដើម្បីបង្កើតជាអំពើអមនុស្សធម៌មួយ វាត្រូវតែបង្ហាញថា ជនរងគ្រោះបានទទួលរងព្យសនកម្មលើរូបកាយ ឬផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ហើយការឈឺចាប់ គឺជាលទ្ធផលនៃអំពីសកម្ម ឬអកម្មរបស់ចារី។ ភាពធ្ងន់ធ្ងរនៃអំពី គឺត្រូវបានធ្វើការវាយតម្លៃដោយផ្អែកតាមករណីនីមួយៗ ដោយពិចារណាទៅលើកាលៈទេសៈបុគ្គលនីមួយៗ។ កាលៈទេសៈទាំងនេះអាចបញ្ចូល "ប្រភេទនៃអំពីសកម្ម ឬអកម្ម បរិបទដែលវាបានកើតឡើង កាលៈទេសៈផ្ទាល់ខ្លួនរបស់ជនរងគ្រោះ រាប់បញ្ចូលទាំង អាយុ ភេទ និងសុខភាព ព្រមទាំងផលប៉ះពាល់ផ្នែកសីលធម៌ ផ្នែកផ្លូវកាយ និងផ្លូវចិត្តនៃអំពើនោះមកលើជនរងគ្រោះ"។ មិនមានលក្ខខណ្ឌតម្រូវថា ការរងទុក្ខនេះត្រូវតែមានផលប៉ះពាល់រយៈពេលយូរអង្វែងឡើយ ទោះបីជាការរងទុក្ខនេះអាចពាក់ព័ន្ធទៅនឹងការធ្វើសេចក្តីសម្រេចអំពីភាពធ្ងន់ធ្ងរនៃអំពើនោះក៏ដោយ។*

***ឧទាហរណ៍នៃអំពើអមនុស្សធម៌ ដែលត្រូវបានរកឃើញថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរាប់បញ្ចូលទាំងការផ្លាស់ទីកន្លែងដោយបង្ខំ និងការជម្លៀសដោយបង្ខំ*** *ព្យសនកម្មលើរូបរាងកាយធ្ងន់ធ្ងរ ការឃុំខ្លួនក្នុងស្ថានភាពរស់នៅដែលមិនអាចទទួលយកបាន និងយ៉ាងព្រៃផ្សៃ ព្រមទាំងការវាយដំ និងអំពើហិង្សាផ្សេងៗទៀត។*

*ចេតនាគ្រប់គ្រាន់ដើម្បីបង្កជាអំពើអមនុស្សធម៌ត្រូវបានបំពេញ នៅពេលដែលចារីមានចេតនាបង្កឱ្យមានការឈឺចាប់រាងកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ឬប្រព្រឹត្តិការវាយប្រហារដ៏ធ្ងន់ធ្ងរមួយទៅលើសេចក្តីថ្លៃថ្នូរជាមនុស្សជាតិរបស់ជនរងគ្រោះ ឬក៏ចារីបានដឹងថាអំពីសកម្ម ឬអកម្ម ទំនងជាបង្កឱ្យមានការឈឺចាប់យ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬផ្លូវចិត្ត ឬការវាយប្រហារដ៏ធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ ចេតនានេះត្រូវតែរកឱ្យឃើញថា មានអត្ថិភាពនៅពេលដែលប្រព្រឹត្តអំពើសកម្ម ឬអកម្មនោះ[៨] ។*

5. អង្គជំនុំជម្រះតុលាការកំពូលមិនទាន់បានសម្រេច ទៅលើនិយមន័យនៃអំពើអមនុស្សធម៌ផ្សេងៗទៀតទេ[9]។ ជាថ្មីម្តងទៀត សារណានេះមិនផ្តោតទៅលើការអធិប្បាយពេញលេញអំពី "អំពើអមនុស្សធម៌ផ្សេងៗទៀត" ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។ ទោះជាយ៉ាងណាក្តី សហព្រះរាជអាជ្ញាពិចារណាថា វាជាការសមហេតុផល ដែលខ្លួនត្រូវធ្វើការសង្កេតដោយសង្ខេបដូចខាងក្រោម។

6. ដូចអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់រួចមកហើយនៅក្នុងអត្ថបទសម្រង់ខាងលើ មិនមានបញ្ហាទេថា ការជម្លៀសមនុស្សដោយបង្ខំមានស្ថានទម្ងន់គ្រប់គ្រាន់ ដើម្បីផ្តល់លក្ខណៈសម្បត្តិថាជាអំពើអមនុស្សធម៌។ ការពិត ដូចដែលបទអត្ថាធិប្បាយរបស់គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម

---

[8] សាលក្រមអង្គជំនុំជម្រះសាលាដំបូងនៃសំណុំរឿង 00១, ឯកសារ E188, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ៣៦៧ ដល់ ៣៧១ (លុបចោលការទាញសំអាងហេតុខាងក្នុង) (គូសបញ្ជាក់បន្ថែម); *សូមមើលផងដែរ* សំណុំរឿង ICTY ដែលត្រូវបានសម្រេចថា ការជម្លៀសដោយបង្ខំគឺជាទង្វើអមនុស្សធម៌ ៖ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* *Vidoje Blagojević & Dragan Jokić*, សំណុំរឿង លេខ IT-02-60-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង I របស់ ICTY, ផ្នែក ក), ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២00៥, កថាខណ្ឌ ៦២៩; *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Momčilo Krajišnik,* សំណុំរឿង លេខ IT-00-39-A, សាលដីកា (អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ICTY), ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២00៩, កថាខណ្ឌ ៣៣១; *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Radoslav Brđanin*, សំណុំរឿង លេខ IT-99-36-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង II របស់ ICTY), ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២00៤, កថាខណ្ឌ ៥៤៤; *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Vujadin Popović និងគូកន,* IT-05-88-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង II របស់ ICTY) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២0១0, កថាខណ្ឌ ៨៨៧ ដល់ ៩៦២; *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Milomir Stakić*, សំណុំរឿង លេខ IT-97-24-A, សាលដីកា (អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ICTY), ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២00៦, កថាខណ្ឌ ៣១៣ ដល់ ៣២១។

[9] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង 00១, ឯកសារ F28, ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២, ជើងទំព័រ ៧៣៣។

ICRC ត្រង់មាត្រា ៤៩ នៃអនុសញ្ញាក្រុងហ្សឺណែវទី៤ ថ្លែងហើយថា "ការនិរទេស ឬការជម្លៀស ដោយខុសច្បាប់ ត្រូវបានបញ្ចូលទៅក្នុងចំណោមការបំពារបំពានធ្ងន់ធ្ងរ ដូចមានកំណត់ក្នុងមាត្រា ១៤៧ នៃអនុសញ្ញានេះ ដែលជាការអំពាវនាវឲ្យមានការផ្តន្ទាទោសធ្ងន់ធ្ងរបំផុត"[10]។

7. ស្រដៀងគ្នានេះដែរ លក្ខន្តិកៈទីក្រុងរ៉ូមបានចាត់ទុកថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃ "អំពើអមនុស្សធម៌ផ្សេងៗទៀតដែលមានលក្ខណៈស្រដៀងគ្នាដែលបង្កឲ្យមានការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា ឬព្យសនកម្មធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាពផ្លូវចិត្ត ឬផ្លូវកាយ"[11]។ ក្នុងការលើកឡើងនូវ "វិសាលភាពសម្រាប់ការបកស្រាយពាក្យថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលមានលក្ខណៈទូលំទូលាយជាងវិសាលភាពនានាដែលមាននៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនោះ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានលើកឡើងនូវប្រភពច្បាប់មួយចំនួនមុននឹងកំណត់យុត្តាធិការរបស់ អ.វ.ត.ក ដោយរួមទាំងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ និងកតិកាសញ្ញាស្តីពីសិទ្ធិមនុស្សចំនួន២ របស់អង្គការសហប្រជាជាតិ ក្នុងឆ្នាំ១៩៦៦[12]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានកត់សម្គាល់ឃើញថា "ដោយសំអាងទៅលើបទប្បញ្ញត្តិនានានៃអត្ថបទទាំងនេះ វាអាចកំណត់អត្តសញ្ញាណនូវសិទ្ធិមូលដ្ឋានមួយចំនួនដែលទាក់ទងនឹងមនុស្សជាតិ ការកំហិតសិទ្ធិដែលអាចសំដៅដល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយអាស្រ័យទៅលើកាលៈទេសៈនានាដែលអមមកជាមួយ"[13]។ តាមរយៈដំណើរការនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "ពាក្យពេចន៍ដែលលើកឡើង [*ពោលគឺ* អំពើអមនុស្សធម៌

---

[10] *បទអត្ថាធិប្បាយ ICRC ស្តីពីអនុសញ្ញាក្រុងហ្សឺណែវទីបួនទាក់ទងនឹងការការពារប្រជាជនស៊ីវិលនៅក្នុងពេលសង្គ្រាម* (១៩៥៨)), ទំព័រ ២៨០ ដោយលោក Oscar Hueler & Henri Coursier ។

[11] លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ, U.N. Doc. A/CONF.183/9 (ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨), មាត្រា ៧(១)(ដ)។

[12] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Zoran Kupreškić និងគូកន,* សំណុំរឿង លេខ IT-95-16-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង ICTY) ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០, កថាខណ្ឌ ៥៦៦។

[13] *ដូចខាងលើ,* កថាខណ្ឌ ៥៦៦។

ផ្សេងៗទៀត] រួមបញ្ចូលដោយឥតសង្ស័យទាំងការជម្លៀសប្រជាជនស៊ីវិលដោយបង្ខំដែរ (ដែលវិសាលភាពខ្លះរបស់វាស្ថិតក្រោមបញ្ញត្តិនៃមាត្រា៤៩ នៃអនុសញ្ញាទី៤ ឆ្នាំ១៩៤៩ ...)"[14]។

8. នៅក្នុង *រឿងក្តី* Stakić អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថាការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀតមិនអាចត្រូវបានចាត់ទុកថាជាការរំលោភដល់គោលការណ៍ *មិនមែនជាបទល្មើសបើគ្មានច្បាប់ចែង (nullem crimen sine lege)* ទេ ដោយសារវាជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[15]។ ក្នុងការគាំទ្រដល់ចំណុចនេះ អង្គជំនុំជម្រះបានដកស្រង់ប្រភពនានាជាច្រើន ដែលមានមុនយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក ទៅទៀត[16]។ ជាងនេះទៀត ដោយយោងទៅដល់មាត្រា ៤៩ នៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ លេខIV អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា ការជម្លៀសដោយបង្ខំត្រូវបានទទួលស្គាល់រួចមកហើយថាជាអំពើដែលត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលវេលាដែលពាក់ព័ន្ធនឹងករណីនេះ ហើយថាអំពើនានានៃការជម្លៀសដោយបង្ខំអាចមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ ដូចអំពើអមនុស្សធម៌ផ្សេងៗទៀតដែរ[17]។

## III. ការជម្លៀសដោយបង្ខំ

9. ដូចដែលនឹងពន្យល់ខាងក្រោម ការនិរទេស និងការជម្លៀសដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ។ ការជម្លៀសដោយបង្ខំកើតចេញពីការនិរទេស ហើយអំពើទាំងពីរនេះការពារផលប្រយោជន៍សាធារណៈដូចគ្នាបេះបិទ ឬស្ទើរតែដូចគ្នាបេះបិទ។ ហេតុនេះ វាជាការសមស្របដើម្បីពិចារណាទៅដល់ការវិវត្តន៍នៃច្បាប់ដែលទាក់ទងនឹងការនិរទេស បន្ថែមទៅលើការជម្លៀសដោយបង្ខំ។

---

[14] *ដូចខាងលើ,* កថាខណ្ឌ ៥៦៦; ប៉ុន្តែសូមមើល *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milomir Stakić,* សំណុំរឿង លេខ IT-97-24-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង II របស់ ICTY), ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣, កថាខណ្ឌ ៧២១, ៧២២ (ឯកភាពមិនប្រើលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សថាជាប្រភពចាំបាច់ ឬជាស្វ័យប្រវត្តិនៃច្បាប់ព្រហ្មទណ្ឌ)។

[15] រឿងក្តី Stakić *សាលីការបស់តុលាការ ICTY, កំណត់សម្គាល់ដូចខាងលើលេខ៨,* កថាខណ្ឌ ៣១៥។

[16] *ដូចខាងលើ,* ជើងទំព័រ ៦៤៩។

[17] *ដូចខាងលើ,* កថាខណ្ឌ ៣១៧។

10. ការនិរទេសត្រូវបានហាមឃាត់ទាំងនៅក្នុងឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[18]។ ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានកត់សម្គាល់ថា "ការនិរទេសជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ វិវត្តពីការនិរទេសក្នុងឧក្រិដ្ឋកម្មសង្គ្រាម ដែលជាវិធីមួយនៃការពង្រីកវិសាលភាពនៃការទប់ស្កាត់មិនឱ្យមានបទល្មើសនេះកើតឡើង ចំពោះជនស៊ីវិលដែលមានសញ្ជាតិដូចចារីដែរ"[19]។

*i. __ប្រវត្តិនៃការហាមឃាត់ការផ្លាស់ទីកន្លែងដោយបង្ខំ__*

11. គោលការណ៍នានាដែលកំណត់ពីការហាមឃាត់ក្នុងការជម្លៀសដោយបង្ខំ អាចត្រូវបានសង្កេតត្រឡប់ទៅវិញលិខិតុបករណ៍អន្តរជាតិនានាដែលកើតមុនសង្គ្រាមលោកលើកទី១ទៅទៀត[20]។ អនុសញ្ញាទីក្រុងឡាអេឆ្នាំ១៨៩៩ និងឆ្នាំ១៩០៧ មានបទប្បញ្ញត្តិដែលកំណត់និយមន័យ និងកំហិតនូវសិទ្ធិរបស់ភាគី

---

[18] *សូមមើលឧទាហរណ៍,* ធម្មនុញ្ញក្រុងឡុងដ៍ស្ដីពីតុលាការយោធាអន្តរជាតិ ("ធម្មនុញ្ញ Nuremberg"), ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥, មាត្រា ៦(ខ) និងមាត្រា ៦(គ); ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ស្ដីពីការផ្ដន្ទាទោសចំពោះបុគ្គលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម, ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងមនុស្សជាតិ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៤៥, ក្រុមប្រឹក្សាគ្រប់គ្រងស្ដីពីការផ្សព្វផ្សាយជាផ្លូវការ ៣ សម្រាប់ប្រទេសអាល្លឺម៉ង់ ៥០ ដល់ ៥៥ (១៩៤៦), មាត្រា II (១)(ខ) និងមាត្រា (១)(គ); អនុសញ្ញាទីក្រុងហ្សឺណែវទីបួន ស្ដីពីការការពារប្រជាជនស៊ីវិលក្នុងពេលសង្គ្រាម, ៧៥ U.N.T.S. ២៨៧, ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០, មាត្រា ៤៩ និងមាត្រា ១៤៧; ពិធីសារបំពេញបន្ថែមទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ, ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងទាក់ទងនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ (ពិធីសារ I), ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៧, មាត្រា ៨៥(ក); ធម្មនុញ្ញតុលាការយោធាអន្តរជាតិនៅចុងបូព៌ា (ធម្មនុញ្ញក្រុងតូក្យូ), ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៤៦, មាត្រា ៥(គ); *Baldur Von Schirach*, សាលក្រម (តុលាការយោធាអន្តរជាតិ, Nuremberg) ថ្ងៃទី ៣០ ខែ កញ្ញា ដល់ថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៤៦; សេចក្ដីព្រាងក្រមស្ដីពីបទល្មើលប្រឆាំងសន្តិភាព និងសន្តិសុខមនុស្សជាតិ, មាត្រា ២(១១) នៅក្នុង*សៀវភៅកំណត់ត្រាប្រចាំឆ្នាំរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ ៖ ១៩៥៤,* ភាគ I (ឆ្នាំ ១៩៥៤); សេចក្ដីព្រាងក្រមស្ដីពីបទល្មើលប្រឆាំងសន្តិភាព និងសន្តិសុខមនុស្សជាតិ, មាត្រា ២០ នៅក្នុង*សៀវភៅកំណត់ត្រាប្រចាំឆ្នាំរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ ៖ ១៩៩៦,* ភាគ II (១៩៩៦); លក្ខន្តិកៈទីក្រុងរ៉ូម, *ដូចខាងលើ* កំណត់សម្គាល់ ១១, មាត្រា ៨(២)(ក)(vii)។

[19] *Stakić*, សាលដីការបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ២៨៩។

[20] សេចក្ដីណែនាំសម្រាប់ការគ្រប់គ្រងកងទ័ពសហរដ្ឋអាមេរិក នៅទីលាន (ក្រមក្រុង Lieber), ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៨៦៣, មាត្រា ២៣ ("ប្រជាជនសាមញ្ញមិនត្រូវ ... បានផ្លាស់ប្ដូរដោយបង្ខំទៅកាន់ទីកន្លែងឆ្ងាយៗ ទៀតឡើយ ...")។

ជម្លោះព្រំដែនដែលចាំបាច់នឹងត្រូវបានបំពានដោយការជម្លៀសដោយបង្ខំ[21]។ អ្នកធ្វើអត្ថាធិប្បាយល្បីៗបានសន្និដ្ឋានថា ការនិរទេសមិនត្រូវបានហាមឃាត់ឱ្យបានច្បាស់លាស់នៅក្នុងអនុសញ្ញាទីក្រុងឡាអេទេ ដោយសារ ការនិរទេស "ត្រូវបានបដិសេធជាទូទៅ ដោយសារវាស្ថិតនៅក្រោមបទដ្ឋានអប្បបរមានៃអរិយធម៌ ហេតុនេះហើយមិនតម្រូវឱ្យធ្វើការហាមឃាត់ច្បាស់លាស់ទេ ភាពខុសច្បាប់នឹងត្រូវគេពិចារណា"[22]។ បន្ទាប់ពីមានការនិរទេសក្នុងអំឡុងសង្គ្រាមលោកលើកទី១នោះមក របាយការណ៍របស់គណៈកម្មការស្តីពីការទទួលខុសត្រូវរបស់ស្ថាបនិកសង្គ្រាមឆ្នាំ១៩១៩ និងស្តីពីការពង្រឹងការផ្តន្ទាទោសបានចាត់ទុកជាផ្លូវការថាការនិរទេសជាបទឧក្រិដ្ឋមួយ[23]។

12. ក្នុងអំឡុងសង្គ្រាមលោកលើកទី២ ការផ្លាស់ប្តូរទីកន្លែងដោយបង្ខំជាច្រើនត្រូវបានធ្វើឡើងក្រោមស្ថានភាពគួរឱ្យរន្ធត់ ហើយជាលទ្ធផលវាបានជំរុញឱ្យមានការផ្តន្ទាទោសជាច្រើន រួមមានភស្តុតាងនៃទម្លាប់អនុវត្តរបស់រដ្ឋ និង *សច្ចធារណ៍ធម្មានុរូប (opinion juris)* នៃការហាមឃាត់នេះ នៅក្រោមច្បាប់

---

[21] សូមមើលអនុសញ្ញា (II) ទាក់ទងនឹងច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាមនៅលើដី និងតំបន់ស្ថិតក្រោមការត្រួតត្រា ៖ បទប្បញ្ញត្តិពាក់ព័ន្ធនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាមលើដី។ ទីក្រុងឡាអេ, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩, មាត្រា ៤៦ និងមាត្រា ៥០; អនុសញ្ញា (IV) ទាក់ទងនឹងច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាមនៅលើដី និងតំបន់ស្ថិតក្រោមការត្រួតត្រា ៖ បទប្បញ្ញត្តិពាក់ព័ន្ធនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាមលើដី។ ទីក្រុងឡាអេ, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧, មាត្រា ៤៦ និងមាត្រា ៥០។

[22] Jean-Marie Henckaerts, *ការនិរទេស និងការជម្លៀសប្រជាជនស៊ីវិល ក្នុងពេលសង្គ្រាម,* ២៦ Vand. J. Transnat'l L. ៤៦៩ (១៩៩៣), ទំព័រ ៤៧២; សូមមើលផងដែរ *បទអត្ថាធិប្បាយ ICRC ស្តីពីអនុសញ្ញាក្រុងហ្សឺណែវទីបួន), ដូចខាងលើ* កំណត់សម្គាល់ ១០, ទំព័រ ២៧៩ ដល់ ២៨០; Alfred De Zayas, *ភាពខុសច្បាប់នៃការជម្លៀសប្រជាជន និងការអនុវត្តបទដ្ឋានអន្តរជាតិដែលកំពុងតែកើតមានក្នុងបរិបទប៉ាឡេស្ទីន),* ៦ Pal. Y.B. Int'l L. 17 (1990-91), ទំព័រ ២១។

[23] *របាយការណ៍របស់គណៈកម្មាធិការស្តីពីការទទួលខុសត្រូវរបស់អ្នកទទួលខុសត្រូវសង្គ្រាម និងការអនុវត្តទោសប្បញ្ញត្តិ)* ១៤ និទានុប្បវត្តិច្បាប់អន្តរជាតិអាមេរិក ៩៥ (១៩២០), ទំព័រ ១១៤។ បន្ទាប់ពីមានរបាយការណ៍របស់គណៈកម្មាធិការ, សន្ធិសញ្ញា ក្រុង Sèvres ឆ្នាំ ១៩២០ ក៏បានចាត់ទុកការនិរទេសថាជាឧក្រិដ្ឋកម្មដែរ។ សូមមើល សន្ធិសញ្ញា ក្រុង Sèvres (ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩២០), មាត្រា ១៤២។ មានសំណើមួយសុំបញ្ចូលការនិរទេសជាឧក្រិដ្ឋកម្មមួយ នៅសន្និបាតកាកបាទក្រហមអន្តរជាតិ ឆ្នាំ ១៩៣៤ ក្នុងទីក្រុងតូក្យូ។ សូមមើលសេចក្តីព្រាងអនុសញ្ញាអន្តរជាតិស្តីពីលក្ខខណ្ឌ និងការការពារប្រជាជនស៊ីវិលដែលត្រូវបានចាត់ទុកថាជាសត្រូវនៅលើទឹកដីមួយដែលជាកម្មសិទ្ធិរបស់ ឬត្រូវបានគ្រប់គ្រងដោយកងទ័ពបច្ចាមិត្រ (ឆ្នាំ ១៩៣៤), មាត្រា ១៩(ខ)។

អន្តរជាតិ[24]។ ក្រោយពេលសង្គ្រាមលោកលើកទី២បញ្ចប់ទៅ ធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ (“ធម្មនុញ្ញតុលាការ Nuremberg”) បានចាត់ថ្នាក់ “ការនិរទេសឱ្យទៅធ្វើជាពលកម្មបែបទាសករ ឬសម្រាប់គោលបំណងផ្សេងៗទៀត ចំពោះប្រជាជនស៊ីវិល ឬនៅក្នុងទឹកដីដែលខ្លួនកាន់កាប់” ជាឧក្រិដ្ឋកម្មសង្គ្រាម[25] និងបានចាត់ថ្នាក់ “ការនិរទេស ... ប្រឆាំងនឹងប្រជាជនស៊ីវិល មុន ឬក្នុងអំឡុងពេលសង្គ្រាម” ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[26]។ បន្ទាប់ពីសង្គ្រាមលោកលើកទី២ នៅឯតុលាការ Nuremberg រដ្ឋអាជ្ញាបានបញ្ចូលបទចោទស្តីពីការនិរទេស[27] ហើយបន្ទាប់មកសាលក្រមនៃតុលាការ Nuremberg បានសន្និដ្ឋានថា ចុងចោទមានពិរុទ្ធពី “ការនិរទេសទៅធ្វើជាពលកម្មបែបទាសករ ឬសម្រាប់គោលបំណងផ្សេងៗទៀត” ជាឧក្រិដ្ឋកម្មសង្គ្រាម និងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[28] សម្រាប់ “ការនិរទេសប្រជាជនយ៉ាងហោចណាស់ចំនួន ៥.០០០.០០០ នាក់ទៅកាន់ប្រទេសអាល្លឺម៉ង់

---

[24] សូមមើល De Zayas, *ការជម្លៀសប្រជាជនក្នុងបរិបទប៉ាឡេស្ទីន, ដូចខាងលើ* កំណត់សម្គាល់ ២៩, ទំព័រ ២១ ដល់ ២២ (ពិភាក្សាអំពីការអនុម័តសេចក្តីសម្រេចសម្ព័ន្ធភាព ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៤២ ស្តីពីឧក្រិដ្ឋកម្មសង្គ្រាមអាល្លឺម៉ង់ ដោយអំពាវនាវឱ្យមានការផ្តន្ទាទោសចំពោះការជម្លៀសទ្រង់ទ្រាយធំដែលធ្វើឡើងដោយប្រទេសអាល្លឺម៉ង់); M. Cherif Bassiouni, *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (១៩៩៩)), ទំព័រ ៣៨៦ (ពិភាក្សាអំពី សេចក្តីព្រាងអនុសញ្ញានៅក្នុងកិច្ចប្រជុំអន្តរជាតិ ឆ្នាំ ១៩៤៣ សម្រាប់តុលាការ ដើម្បីជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម នៅក្នុងយុត្តាធិការរបស់ខ្លួន បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ ពាក់ព័ន្ធនឹងការនិរទេស ដែលបទល្មើសអន្តរជាតិត្រូវតែផ្តន្ទាទោស)។

[25] ធម្មនុញ្ញ Nuremberg, *ដូចខាងលើ* កំណត់សម្គាល់ ២៥, មាត្រា ៦(ខ)។

[26] *ដូចខាងលើ,* មាត្រា ៦(គ)។ សូមមើល *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milorad Krnojelac*, សំណុំរឿង លេខ IT-97-25-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង II របស់ ICTY), ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០២, កថាខណ្ឌ ៤៧៣ (ដោយផ្តល់ការពន្យល់ថា ការនិរទេសពីដំបូងមិនត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ ដើម្បីពង្រីកយុត្តាធិការដើម្បីរួមបញ្ចូលជនប្រព្រឹត្តល្មើសដែលមានសញ្ជាតិដូចគ្នានឹងអ្នកត្រូវបានគេជម្លៀស)។

[27] បទចោទលេខ ៣ ក្នុងដីកាចោទប្រកាន់របស់តុលាការយោធាអន្តរជាតិ (១៩៤៥); កំណត់សម្គាល់ ៦៣ Bassiouni, *ដូចខាងលើ* កំណត់សម្គាល់ ៣១, ទំព័រ ៣៨៧។

[28] សាលក្រមរៀបរាប់អំពីឧក្រិដ្ឋកម្មនានាដែលមានចែងនៅក្នុងមាត្រា ៦(ខ) ដែលជាមាត្រាទប់ស្កាត់ឧក្រិដ្ឋកម្មសង្គ្រាម ប៉ុន្តែក្រោយមកបានបង្ហាញថា ឧក្រិដ្ឋកម្មទាំងនេះក៏ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ។

ដើម្បីធ្វើការនៅផ្នែកឧស្សាហកម្ម និងកសិកម្ម"[29]។ គោលការណ៍ច្បាប់ដែលមាននៅក្នុងធម្មនុញ្ញតុលាការ Nuremberg និងសាលក្រមតុលាការ Nuremberg ត្រូវបានបញ្ជាក់គាំទ្រដោយមហាសន្និបាតអង្គការសហប្រជាជាតិ[30] ហើយបន្ទាប់មកត្រូវបានគណៈកម្មការច្បាប់អន្តរជាតិយកទៅចងក្រងជាច្បាប់[31]។

13. ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០[32] និង ធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា[33] បានប្រកាសជាផ្លូវការថា ការនិរទេសជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ដោយផ្អែកលើច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ តុលាការនៅតាមតំបន់នានានៅប្រទេសអាល្លឺម៉ង់បានបញ្ចូលការផ្តន្ទាទោសចំពោះបទល្មើសនិរទេស[34]។ ករណីទាំងនេះដែលមានឥទ្ធិពលនៅចំពោះមុខតុលាការយោធា ស.រ.អា បាន

---

[29] សូមមើលសាលក្រម តុលាការយោធាអន្តរជាតិនៅ Nuremberg ដើម្បីជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមសំខាន់ដែលជាជនជាតិអាល្លឺម៉ង់ ថ្ងៃទី ៣០ ខែ កញ្ញា ដល់ថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៤៦។ ទាក់ទងនឹងឧក្រិដ្ឋកម្មសង្គ្រាម, សាលក្រមលើកឡើងថា "ប្រជាជនទាំងមូលត្រូវបានជម្លៀសទៅប្រទេសអាល្លឺម៉ង់ក្នុងគោលបំណងយកទៅធ្វើការងារដោយបង្ខំ ដូចជាការងារការពារ, ការផលិតសម្ភារៈសឹក និងការងារផ្សេងៗទៀតដែលទាក់ទងនឹងសង្គ្រាម" *ដូចខាងលើ,* ទំព័រ ៤៥០។

[30] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៩៥ (I), *ការសម្រេចគាំទ្រលើគោលការណ៍ច្បាប់អន្តរជាតិដែលបានទទួលស្គាល់ដោយធម្មនុញ្ញតុលាការ Nuremberg*, ដែលបានអនុម័ត នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦។

[31] គោលការណ៍ច្បាប់អន្តរជាតិបានទទួលស្គាល់នៅក្នុងធម្មនុញ្ញរបស់តុលាការ Nürnberg និងនៅក្នុងសាលក្រមនៃតុលាការនេះ នៅក្នុង *សៀវភៅកំណត់ត្រាប្រចាំឆ្នាំរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ ៖ ១៩៥០)*, ភាគ II, ទំព័រ ៣៧៤។ សូមមើលផងដែរ Alfred de Zayas, "ការជម្លៀសប្រជាជនដោយបង្ខំ" នៅក្នុង*សព្វវចនាធិប្បាយផ្នែកច្បាប់សាធារណៈអន្តរជាតិ ដែលរៀបរៀងដោយ Max Planck*) (២០១២), កថាខណ្ឌ ២០។

[32] ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង, *ដូចខាងលើ* កំណត់សម្គាល់ ២៥, មាត្រា II(១)(គ)។ មាត្រា II(១)(ខ) បានទទួលស្គាល់ការនិរទេសថាជាឧក្រិដ្ឋកម្មសង្គ្រាម។

[33] តុលាការយោធាអន្តរជាតិចុងបូព៌ា ("ធម្មនុញ្ញតូក្យូ"), ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៤៦, មាត្រា ៥(គ)។

[34] *សាលក្រមនៃរឿងក្តី versus Hermann Roechling និងគូកនដែលរងការចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព, ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ* (តុលាការទូទៅនៃការគ្រប់គ្រងយោធាក្នុងតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់បារាំង ក្នុងប្រទេសអាល្លឺម៉ង់), ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៤៨, ឧបសម្ព័ន្ធ ខ, ទំព័រ ១០៨៦, កថាខណ្ឌ ៦; *សវនាការរឿងក្តី Carl Krauch និងមនុស្ស ២២ នាក់ផ្សេងទៀត* ("សវនាការរឿងក្តី I.G. Farben") (តុលាការយោធាសហរដ្ឋអាមេរិក, Nuremberg), ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ១៩៤៧ ដល់ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៤៨, ទំព័រ ៤ ដល់ ៥, ទំព័រ ៥៧; *សវនាការលើរឿងក្តី Erhard Milch* (តុលាការយោធាសហរដ្ឋអាមេរិក, Nuremberg), ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៤៦ ដល់ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៤៧, ទំព័រ ២៧ ដល់

បញ្ជាក់ថា ការនិរទេសគឺឧក្រិដ្ឋកម្មសង្គ្រាម និងបានអះអាងយ៉ាងច្បាស់ថា ការនិរទេសជនស៊ីវិលសម្រាប់ធ្វើការងារ សូម្បីតែការងារមិនត្រូវបានប្រើដោយផ្ទាល់ដែលទាក់ទងនឹងប្រតិបត្តិការណ៍សង្គ្រាមក៏ដោយ ក៏អំពើនេះមិនត្រូវបានផ្តន្ទាទោសតាមច្បាប់អន្តរជាតិដែរ[35]។ តុលាការនៅប្រទេសចិន[36] ប៉ូឡូញ[37] ហូឡង់[38] និងអ៊ីស្រាអែល[39] ក៏បានសម្រេចឱ្យបុគ្គលមានពិរុទ្ធភាពចំពោះបទល្មើសនិរទេសដែលបានប្រព្រឹត្តក្នុងអំឡុងសង្គ្រាមលោកលើកទី២ ដែរ។

---

២៨; *សវនាការលើរឿងក្តី Alfried Felix Alwyn, Krupp តទល់នឹង Bohlen, und Halbach និង ១១ នាក់ផ្សេងទៀត (“សវនាការ Krup”)* (តុលាការយោធាសហរដ្ឋអាមេរិក, Nuremberg), ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៤៧ ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៤៨, ទំព័រ ៧៤; *សវនាការលើរឿងក្តី Wilhelm List និងអ្នកផ្សេងៗទៀត (“សវនាការ The Hostages”)* (តុលាការយោធាសហរដ្ឋអាមេរិក, Nuremberg) សាលក្រម, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៤៨, ទំព័រ ១៣០៥; *សហរដ្ឋអាមេរិក តទល់នឹង Wilhelm von Leeb និងអ្នកផ្សេងទៀត,* (តុលាការយោធាសហរដ្ឋអាមេរិក, Nuremberg), សាលក្រម, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៤៨, ទំព័រ ៨៤; Flick *និងអ្នកផ្សេងទៀត,* (តុលាការយោធាសហរដ្ឋអាមេរិក, Nuremberg), សាលក្រម, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៤៧ នៅក្នុង *សវនាការលើឧក្រិដ្ឋជនសង្គ្រាម នៅចំពោះមុខតុលាការយោធា Nuremberg*, ភាគ VI, ទំព័រ ១១៨៣, ទំព័រ ១២០១។

[35] *Milch*, សាលក្រមរបស់តុលាការយោធានអន្តរជាតិ (IMT), *ដូចខាងលើ* កំណត់សម្គាល់ ៤១, ទំព័រ ៨៤៩; *Krupp*, សាលក្រមរបស់តុលាការយោធានអន្តរជាតិ, *ដូចខាងលើ* កំណត់សម្គាល់ ៤១, ទំព័រ ៨៤ ដល់ ៨៧។

[36] *Trial of Takashi Sakai* (តុលាការយោធាចិនផ្នែកឧក្រិដ្ឋកម្មសង្គ្រាមនៃក្រសួងការពារជាតិ, ក្រុង Nanking) ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៤៦។

[37] *នៅក្នុងរឿងក្តី re Greiser*, សាលដីកានៃតុលាការកំពូលជាតិនៃប្រទេសប៉ូឡូញ នៅ Poznan, ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ១៩៤៦, បានសង្ខេបនៅក្នុង*កម្រងអត្ថបទសង្ខេប និងរបាយការណ៍ប្រចាំឆ្នាំស្តីពីរឿងក្តីនៃច្បាប់សាធារណៈអន្តរជាតិ*, ភាគ ១៣ (ឆ្នាំ ១៩៤៦), ទំព័រ ៣៨៧; សូមមើលផងដែរ *សវនាការរឿងក្តី Gauleiter Artur Greiser*, តុលាការកំពូលជាតិនៃប្រទេសប៉ូឡូញ, បានសង្ខេបនៅក្នុង *កម្រងអត្ថបទសង្ខេប និងរបាយការណ៍ប្រចាំឆ្នាំស្តីពីរឿងក្តីនៃច្បាប់សាធារណៈអន្តរជាតិ*, ភាគ ១៣ (ឆ្នាំ ១៩៤៦), ទំព័រ ៨៦, ទំព័រ ១១២, ទំព័រ ១១៣។

[38] *នៅក្នុងរឿងក្តី re Zimmermann*, សាលដីកានៃតុលាការកំពូលពិសេស, ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៤៩, បានសង្ខេបនៅក្នុង*កម្រងអត្ថបទសង្ខេប និងរបាយការណ៍ប្រចាំឆ្នាំស្តីពីរឿងក្តីនៃច្បាប់សាធារណៈអន្តរជាតិ*, ភាគ ១៦ (១៩៤៩), ទំព័រ ៥៥២។

[39] *អគ្គរដ្ឋអាជ្ញា តទល់នឹង Adolf Eichmann*, សំណុំរឿង លេខ ៤០/៦១, សាលក្រម (តុលាការស្រុក Jerusalem), ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៦១។

14. ក្រៅពីការផ្តន្ទាទោស និងការចោទប្រកាន់ដល់ការនិរទេស និងការជម្លៀសដោយបង្ខំ នៅមុនពេល អំឡុងពេល និងក្រោយសង្គ្រាមលោកលើកទី១ និងទី២ នោះមក ទម្រង់ជាក់លាក់មួយចំនួននៃការនិរទេសត្រូវបានលើកលែងដោយសហគមន៍អន្តរជាតិក្នុងអំឡុងពេល និងក្រោយពេលមានអរិភាពភ្លាម[40]។ ទោះជាយ៉ាងណាក្តី នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ សហគមន៍អន្តរជាតិបានបដិសេធការនិរទេសទៅតាមប្រភេទ ដោយអនុម័តមាត្រា៤៩ ដែលហាមឃាត់មិនឱ្យមានការជម្លៀស ឬនិរទេសជនស៊ីវិល ទោះបីជាអនុញ្ញាតសម្រាប់ការផ្លាស់ទីកន្លែងប្រជាជនបណ្តោះអាសន្នដែលត្រូវធ្វើដើម្បីសន្តិសុខរបស់ប្រជាជន ឬ "មូលហេតុអាថ្វាបញ្ជាររបស់យោធា"[41] ក៏ដោយ។ តុលាការ ICTY បានទទួលស្គាល់ថា ទោះបីការហាមឃាត់ដែលមាននៅក្នុងមាត្រា៤៩ កើតចេញពីព្រឹត្តិការណ៍នានាក្នុងសង្គ្រាមលោកលើកទី២ក៏ដោយ ក៏ *"ធាតុផ្សំសំខាន់ៗនៃមាត្រា៤៩(១) ដូចជា ការហាមឃាត់ដាច់ខាតមិនឱ្យមានការជម្លៀសប្រជាជនជាទ្រង់ទ្រាយធំ និងជម្លៀសបុគ្គលម្នាក់ៗដោយបង្ខំ និងការនិរទេសជនដែលត្រូវបានការពារពីទឹកដីដែលស្ថិតក្រោមការកាន់កាប់ ដូចមានចែងក្នុងមាត្រា៤៩(១) គឺជាការ*

---

[40] តួកគី, ក្រិក និងប៊ុលហ្គារី មានការពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំនៃប្រជាជនស៊ីវិល បន្ទាប់ពីសង្គ្រាមលោកលើកទី ១។ នៅក្នុងឆ្នាំ ១៩៣៩, សហភាពសូវៀត បាននិរទេសប្រជាជនប៉ូឡូញខាងកើតទៅកាន់តំបន់ផ្សេងទៀតនៃសហភាពសូវៀត។ នៅក្នុងអំឡុងពេលសង្គ្រាមលោកលើកទីពីរ សហរដ្ឋអាមេរិក និងកាណាដាបានជម្លៀសពូជពង្សជនជាតិជប៉ុន នៅក្នុងប្រទេសទាំងពីរនេះ។ ប្រជាជនអាល្លឺម៉ង់ និងជនជាតិភាគតិចត្រូវបានជម្លៀសដោយបង្ខំពីស្រុកកំណើតរបស់ខ្លួនទៅកាន់ប្រទេសអឺរ៉ុបមួយចំនួន ដោយផ្អែកលើការយល់ព្រមយ៉ាងស្ងៀមស្ងាត់ពីប្រទេសមហាអំណាចដែលបានទទួលជោគជ័យនៅក្នុងសង្គ្រាមលោកលើកទីពីរ។ សូមមើល Bassiouni, *ដូចខាងលើ* កំណត់សម្គាល់ ៣១, ទំព័រ ៣៨៨; Alfred de Zayas, *ច្បាប់អន្តរជាតិ និងការជម្លៀសប្រជាជនទ្រង់ទ្រាយធំ*, ១៦ Harv. Int'l. L. J. ២០៧ (១៩៧៥), ទំព័រ ២១៣, ជើងទំព័រ ២២, ជើងទំព័រ ២២២, ជើងទំព័រ ២២៥ ដល់ ២២៦។

[41] អនុសញ្ញាក្រុងហ្សឺណែវទីបួន, *ដូចខាងលើ* កំណត់សម្គាល់ ២៤, មាត្រា ៤៩។ ការនិរទេសដោយខុសច្បាប់ ក៏ជា "ការរំលោភធ្ងន់ធ្ងរ" ក្នុងមាត្រា ១៤៧ នៃអនុសញ្ញាក្រុងហ្សឺណែវទីបួន និងអាចជាការរំលោភមាត្រារួម ៣ នៃ អនុសញ្ញាទីក្រុងហ្សឺណែវ ដែលទប់ស្កាត់ "ការរំលោភជីវិត និងមនុស្ស" និង "ការប្រមាថធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូរផ្ទាល់"។ សូមមើល *ដូចខាងលើ,* មាត្រា ១៤៧; de Zayas, *ការជម្លៀសប្រជាជនទ្រង់ទ្រាយធំ*, *ដូចខាងលើ* កំណត់សម្គាល់ ៤៧, ទំព័រ ២២១។

*ប្រកាសនូវច្បាប់ទំនៀមទម្លាប់ សូម្បីតែនៅពេលដែលកម្មវត្ថុ និងការរៀបចំនៃការនិរទេសខុសពីកម្មវត្ថុ និងការរៀបចំដែលមានក្នុងទម្លាប់អនុវត្តរបស់ អាល្លឺម៉ង់ក្នុងសង្គ្រាមលោកលើកទី២ ក៏ដោយ...*"[42]។

15. ចាប់តាំងពីមានអនុសញ្ញាទីក្រុងហ្សឺណែវ និងមុននឹងមានពេលវេលាពាក់ព័ន្ធក៏ដោយ ក៏លិខិតុបករណ៍ក្នុងតំបន់ និងអន្តរជាតិមួយចំនួនបានហាមឃាត់ការនិរទេស និង/ឬការជម្លៀសដោយបង្ខំរួចទៅហើយ (និងសិទ្ធិពាក់ព័ន្ធដែលត្រូវបានការពារ) នៅពេលមានសន្តិភាព[43]។ បន្ថែមទៅលើសៀវភៅយោធាមួយចំនួនដែលត្រូវបានបោះពុម្ពផ្សាយមុននឹងមានពេលវេលានៃការជម្លៀសដោយបង្ខំដែលពាក់ព័ន្ធ ក៏បានហាមឃាត់ការផ្លាស់ទីកន្លែងដោយបង្ខំដែរ[44]។ លិខិតុបករណ៍នាពេលថ្មីៗនេះជាច្រើនក៏បានដោះស្រាយការហាមឃាត់ការនិរទេស និងការជម្លៀសប្រជាជនដែរ[45]។ បើតាមលក្ខន្តិកៈតុលាការ ICTR[46] តុលាការ ICTY[47] និង

---

[42] *Krnojelac,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៣៣, កថាខណ្ឌ ៤៧៣, ជើងទំព័រ ១៤២២។

[43] Bassiouni, *ដូចខាងលើ* កំណត់សម្គាល់ ៣១, ទំព័រ ៣៩២។ សូមមើល សេចក្តីសម្រេចលេខ ២១៧ ក(III) នៃមហាសន្និបាតអង្គការសហប្រជាជាតិ, *សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស,* ដែលបានអនុម័តនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨, មាត្រា ៣, មាត្រា ៥, មាត្រា ១២, មាត្រា ១៣(១); អនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ("អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស") ២១៣ U.N.T.S. ២២១, ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៥០, មាត្រា ២; ពិធីសារលេខ ៤ ស្តីពីអនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន, ធានាពីសិទ្ធិ និងសេរីភាពមួយចំនួន ក្រៅពីសិទ្ធិនានាដែលមានចែងរួចហើយនៅក្នុងអនុសញ្ញាក្នុងពិធីសារដំបូង, ETS ៤៦, ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ១៩៦៨, មាត្រា ២, មាត្រា ៣, មាត្រា ៤; អនុសញ្ញាទាក់ទងនឹងស្ថានភាពនៃជនភៀសខ្លួន, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៥១, ១៨៩ U.N.T.S. ១៥០, មាត្រា ៣២; កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦, 999 U.N.T.S. 171, មាត្រា ១២, មាត្រា ១៣; អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស, ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៦៩, 1144 U.N.T.S. 143, មាត្រា ២២(៥), មាត្រា ២២(៩); សេចក្តីព្រាងក្រម ILC ឆ្នាំ ១៩៥៤, *ដូចខាងលើ* កំណត់សម្គាល់ ២៤, មាត្រា ១១។

[44] *ឯកសារណែនាំនៅរបស់សហរដ្ឋអាមេរិកនៅពេលមិននៅលើទីលាន(១៩៥៦); ឯកសារណែនាំយោធារបស់ចក្រភពអង់គ្លេស (១៩៥៨); ឯកសារច្បាប់សង្គ្រាមរបស់ប្រទេសអាហ្សង់ទីន (១៩៦៩);* គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ, *ច្បាប់ទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ ភាគ ១ ៖ វិធាន* (២០០៩) ទំព័រ xxxvii-xxxviii (ពិភាក្សាអំពីឯកសារណែនាំយោធាថាជាប្រភពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ)។

[45] ពិធីសារបំពេញបន្ថែមទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ, ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងពាក់ព័ន្ធទៅនឹងការការពារជនរងគ្រោះនិងជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ (ពិធីសារទីពីរ), 1125 U.N.T.S 609, ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ១៩៧៨, មាត្រា ១៧; សេចក្តីព្រាងក្រមឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ, មាត្រា ២២(២)(ក) នៅក្នុង*សៀវភៅកំណត់ត្រាប្រចាំឆ្នាំរបស់*

តុលាការ ICC[48] ការនិរទេស និងការជម្លៀសប្រជាជនដោយបង្ខំ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។

ii. *ការវិភាគទៅលើការជម្លៀសដោយបង្ខំពឹងផ្អែកយ៉ាងសមរម្យលើការវិភាគនៃការនិរទេស*

16. ទោះបីឧក្រិដ្ឋកម្មដែលមានទម្រង់ជាការនិរទេស និងការជម្លៀសដោយបង្ខំមានភាពខុសគ្នាក៏ដោយ ក៏ការវិភាគរួមគ្នាទៅលើឧក្រិដ្ឋកម្មទាំងពីរនេះជាការសមរម្យ ដោយផ្អែកទៅលើប្រវត្តិរួមគ្នារបស់ឧក្រិដ្ឋកម្មទាំងពីរដូចបានបង្ហាញជូនខាងលើ ធាតុផ្សំដែលស្ទើរតែដូចគ្នាបេះបិទ[49] និងគោលបំណងរួមរបស់ឧក្រិដ្ឋកម្មទាំងពីរគឺ ដើម្បីការពារសិទ្ធិ និងគោលការណ៍ដូចគ្នា[50]។ "ទាំងការនិរទេស ទាំងការជម្លៀសដោយខុសច្បាប់ មានទំនាក់ទំនងទៅនឹងការផ្លាស់ទីដោយមិនស្ម័គ្រចិត្ត និងមិនស្របច្បាប់ ឬការផ្លាស់ទី

---

*គណៈកម្មាធិការច្បាប់អន្តរជាតិ ៖ ១៩៩១* , ភាគ I; សេចក្តីព្រាងក្រម ILC ឆ្នាំ ១៩៩៦, *ដូចខាងលើ* កំណត់សម្គាល់ ២៤, មាត្រា ២០(ក) (vii); គណៈកម្មាធិការអង្គការសហប្រជាជាតិសម្រាប់សិទ្ធិមនុស្ស, *របាយការណ៍របស់តំណាងអគ្គលេខាធិការ លោក Francis M. Deng, បានដាក់ជូន អនុលោមតាម សេចក្តីសម្រេចរបស់គណៈកម្មាធិការ លេខ ១៩៩៧/៣៩។ ឯកសារបន្ថែម ៖ គោលការណ៍ណែនាំស្តីពីការជម្លៀសក្នុងប្រទេស,* ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៨, គោលការណ៍ទី ៥; អនុគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស, *សិទ្ធិមនុស្ស និងការជម្លៀសប្រជាជន, ឧបសម្ព័ន្ធ II ៖ សេចក្តីព្រាងសេចក្តីថ្លែងការណ៍ស្តីពីការជម្លៀសប្រជាជន និងការបញ្ចូលអ្នកតាំងទីលំនៅ,* ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៧, មាត្រា ៣។

[46] លក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉ាន់ដា U.N. Doc. S/RES/955 (ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤), មាត្រា ៣(ឃ) (ដោយកំណត់ការនិរទេសជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប៉ុន្តែមិនបានផ្តល់និយមន័យពីឧក្រិដ្ឋកម្មដូចនេះទេ)។

[47] លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, U.N. Doc S/RES/827 (ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣), មាត្រា ២(ឆ) (ដោយកំណត់ "ការនិរទេស ឬការជម្លៀសខុសច្បាប់" ថាជាការរំលោភធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ), មាត្រា ៥(ឃ) (ដោយកំណត់ការនិរទេសជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប៉ុន្តែមិនបានផ្តល់និយមន័យពីឧក្រិដ្ឋកម្មដូចនេះទេ)។

[48] លក្ខន្តិកៈទីក្រុងរ៉ូម, *ដូចខាងលើ* កំណត់សម្គាល់ ១១, មាត្រា ៧(១)(ឃ), មាត្រា ៧(២)(ឃ), មាត្រា ៨.២(ក) (vii), មាត្រា ៨.២(ង) (viii)។

[49] Bassiouni, *ដូចខាងលើ* កំណត់សម្គាល់ ៣១, ទំព័រ ៣៩៣។

[50] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Blagoje Simić និងអ្នកផ្សេងទៀត,* សំណុំរឿង លេខ IT-95-9-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង II របស់ ICTY), ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៣, កថាខណ្ឌ ១៣០។

កន្លែង ឬការយកទៅដាក់នៅទីតាំងថ្មី ឬការបណ្តេញប្រជាជនចេញពីទឹកដីដែលពួកគេរស់នៅ"[51]។ ក្នុងការសន្និដ្ឋានថា ការនិរទេសត្រូវបានបង្កើតឡើងនៅក្នុងច្បាប់អន្តរជាតិនោះ អង្គជំនុំជម្រះសាលាដំបូងមួយនៃតុលាការ ICTY បានកត់សម្គាល់ថា ទោះបីលិខិតុបករណ៍នាពេលនោះឆ្លើយតបនឹង "ការនិរទេស" ក៏ដោយ ក៏ការអនុវត្តជាបទព្រហ្មទណ្ឌបានលាតសន្ធឹងទៅដល់ការជម្លៀសដោយបង្ខំផងដែរ "ដោយមិនគិតដល់ថា តើការផ្លាស់ទីបានធ្វើឡើងឆ្លងកាត់ព្រំដែនអន្តរជាតិ ឬក៏អត់នោះទេ"[52]។ អង្គជំនុំជម្រះដដែលនេះក៏បានកត់សម្គាល់ផងដែរថា "នៅក្នុង *រឿងក្តី Attorney General តទល់នឹង Adolf Eichmann* តុលាការក្រុងហ្សេរុយសាឡឹមបានសន្និដ្ឋានថា Adolf Eichmann មានពិរុទ្ធភាពពីការនិរទេសចំពោះអំពើនៃការផ្លាស់ទីប្រជាជនក្នុងប្រទេស"[53]។

17. ព្យសនកម្មរួមមួយចំនួនកើតឡើងដោយសារ ការនិរទេស និងការជម្លៀសដោយបង្ខំ រួមមាន ការរំលោភដល់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងសិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គម និងការបៀតបៀនដល់រាងកាយ[54]។ អ្នកផ្តល់ការអត្ថាធិប្បាយម្នាក់បានអះអាងថា ការជម្លៀសដោយបង្ខំ *"បង្កើតជាការចរចាពីសិទ្ធិស្វ័យសម្រេច ដោយសារពុំមានបុគ្គលណាម្នាក់ ឬសហគមន៍ណាមួយ អាចអនុវត្តសិទ្ធិជាសារវន្តនេះបានទេ ប្រសិនបើបុគ្គល ឬសហគមន៍នោះត្រូវបានបណ្តេញចេញ"*[55]។

---

[51] *ដូចខាងលើ,* កថាខណ្ឌ ១២១ (ការដកស្រង់ផ្នែកក្នុងត្រូវបានលុបចេញ)។

[52] *Stakić*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ១៤, កថាខណ្ឌ ៦៨៥ (ក៏បានគាំទ្រដល់គោលការណ៍ដោយយោងលើសាលក្រម Nuremberg ត្រង់ផ្នែកនិរទេស)។

[53] *ដូចខាងលើ,* កថាខណ្ឌ ៦៨៥។

[54] De Zayas, *ការជម្លៀសប្រជាជនដោយបង្ខំ ដែលរៀបរៀងដោយ Max Planck, ដូចខាងលើ* កំណត់សម្គាល់ ៣៨, កថាខណ្ឌ ១២ (ដោយដកស្រង់ពីសេចក្តីថ្លែងការណ៍របស់លោក José Ayala Lasso ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដែលបានថ្លែងនៅក្នុងសន្និសីទមួយស្តីពីការជម្លៀសប្រជាជន ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ក្នុងទីក្រុងហ្សឺណែវ)។

[55] *ដូចខាងលើ,* កថាខណ្ឌ ១៣ ("ស្វ័យសម្រេចត្រូវបានចែងនៅក្នុងមាត្រា ១, មាត្រា ៥៥, មាត្រា ៧៣ និង មាត្រា ៧៦ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ, ក្នុងសេចក្តីថ្លែងការណ៍ស្តីពីគោលការណ៍នៃច្បាប់អន្តរជាតិ និងក្នុងមាត្រា ១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ឆ្នាំ ១៩៦៦)។

18. អង្គជំនុំជម្រះសាលាដំបូងចំនួន ៣ នៃតុលាការ ICTY បានវាយតម្លៃពីព្យសនកម្មដែលបានកើតឡើងដោយសារការផ្លាស់ទីកន្លែងដោយបង្ខំ ទោះបីជាឆ្លងកាត់រដ្ឋ ឬនៅក្នុងរដ្ឋក៏ដោយ ដោយកត់សម្គាល់ថា (១) "បើតាមនិយមន័យ ការផ្លាស់ទីដោយបង្ខំគឺជាបទពិសោធន៍គួរឱ្យតក់ស្លុតដែលពាក់ព័ន្ធនឹងការបោះបង់ចោលផ្ទះសម្បែង ការបាត់បង់ទ្រព្យសម្បត្តិ និងត្រូវបានផ្លាស់ទីដោយការបង្ខិតបង្ខំទៅកាន់កន្លែងមួយទៀត"[56] (២) "ក្នុងចំណោមតម្លៃផ្លូវច្បាប់ដែលត្រូវបានការពារដោយការនិរទេស និងការជម្លៀសដោយបង្ខំគឺជាសិទ្ធិរបស់ជនរងគ្រោះក្នុងការស្នាក់នៅផ្ទះសម្បែង និងក្នុងសហគមន៍របស់ខ្លួន និងសិទ្ធិនោះមិនត្រូវដកហូតទ្រព្យសម្បត្តិរបស់គាត់ ដោយការបង្ខំឱ្យផ្លាស់ទីទៅកាន់កន្លែងមួយទៀត"[57] និង (៣)៖ "ផលប្រយោជន៍ដែលត្រូវបានការពារខាងក្រោយការហាមឃាត់មិនឱ្យមានការនិរទេស គឺសិទ្ធិ និងការរំពឹងរបស់បុគ្គលម្នាក់ៗថាអាចនឹងនៅក្នុងផ្ទះសម្បែង និងសហគមន៍របស់ខ្លួនបាន ដោយគ្មានការជ្រៀតជ្រែកពីអ្នកឈ្លានពាន ទោះបីមកពីរដ្ឋតែមួយ ឬរដ្ឋមួយទៀតក៏ដោយ"[58] អង្គជំនុំជម្រះសាលាដំបូងទី៤ បានអះអាងថា៖ "ការហាមឃាត់មិនឱ្យមានការផ្លាស់ទីដោយបង្ខំមានគោលបំណងការពារសិទ្ធិ និងសេចក្តីប្រាថ្នារបស់បុគ្គលម្នាក់ៗ ក្នុងការរស់នៅក្នុងសហគមន៍ និងផ្ទះសម្បែងរបស់ខ្លួន ដោយគ្មានការជ្រៀតជ្រែកពីអ្នកខាងក្រៅ"[59]។

19. ដូចដែលអង្គជំនុំជម្រះសាលាដំបូងលើ*រឿងក្តី* *Stakić* បានសម្រេចរួចហើយថា ទោះបីឆ្លងកាត់ព្រំដែនអន្តរជាតិក្តី ឬមិនឆ្លងព្រំដែនក្តី ទិសដៅនៃការផ្លាស់ទីកន្លែងជាបញ្ហាបន្ទាប់បន្សំតែប៉ុណ្ណោះ បញ្ហាសំខាន់គឺថា ការផ្លាស់ទីលំនៅគឺជាមូលហេតុដែលបណ្តាលឱ្យមានព្យសនកម្ម។ ទោះបីអង្គជំនុំជម្រះសាលា

---

[56] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Radislav Krstić*, សំណុំរឿង លេខ IT-98-33-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង ICTY), ថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០១, កថាខណ្ឌ ៥២៣។

[57] *Blagoje Simić និងអ្នកផ្សេងទៀត*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៥៧, កថាខណ្ឌ ១៣០។

[58] *Stakić*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ១៤, កថាខណ្ឌ ៦៧៧។

[59] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milorad Krnojelac*, សំណុំរឿង លេខ IT-97-25-A, សាលដីកា (អង្គជំនុំជម្រះតុលាការកំពូល ICTY), ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣, កថាខណ្ឌ ២១៨។

ដំបូងដទៃទៀតនៃតុលាការ ICTY មិនយល់ស្របនឹង *រឿងក្តី Stakić* ទាក់ទងនឹងនិយមន័យនៃពាក្យថា ការនិរទេសក៏ដោយ[60] តែគោលការណ៍ដែលថា ពន្យសនកម្មជាមូលដ្ឋានដែលកើតឡើង ដោយសារការជម្លៀសដោយបង្ខំ និងការនិរទេស មានឧត្តមភាពនោះ នៅមានសុពលភាពនៅឡើយ។ ដូចដែលតុលាការ ICTY បានអះអាងក្នុង *រឿងក្តី Stakić* រួចមកហើយថា៖

> *ផលប្រយោជន៍ដែលត្រូវបានការពារ ខាងក្រោយការហាមឃាត់មិនឱ្យមានការនិរទេស គឺសិទ្ធិ និងការរំពឹងរបស់បុគ្គលម្នាក់ៗថាអាចនឹងនៅក្នុងផ្ទះសម្បែង និងសហគមន៍របស់ខ្លួនបាន ដោយគ្មានការជ្រៀតជ្រែកពីអ្នកល្លុកពាន ទោះបីមកពីរដ្ឋតែមួយ ឬរដ្ឋមួយទៀតក៏ដោយ។ សំណួរនៅត្រង់ថា តើព្រំដែនមួយត្រូវបានទទួលស្គាល់ជាអន្តរជាតិហើយ ឬនៅ បើមិនដូច្នោះទេ ត្រឹមតែព្រំដែនជាក់ស្តែងនោះ មិនមែនជាការសំខាន់ទេ*[61] ។

*iii.* <u>*និយមន័យ និងធាតុផ្សំនៃការជម្លៀសដោយបង្ខំ*</u>

20. ទាំងពាក្យ "ការនិរទេស" ទាំងពាក្យ "ការជម្លៀសដោយបង្ខំ" មានន័យថាជាការផ្លាស់ទីលំនៅមនុស្សដោយបង្ខំពីតំបន់ដែលពួកគេមានវត្តមានត្រឹមត្រូវតាមច្បាប់ ដោយគ្មានហេតុផលដែលបានអនុញ្ញាតក្រោមច្បាប់អន្តរជាតិឡើយ[62]។ "ការជម្លៀសដោយបង្ខំ"[63] ទាក់ទិនទៅនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខិត

---

[60] *Brđanin*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៥៤១ ដល់ ៥៤២ (ដោយកត់សម្គាល់ថា *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Stakic គឺជារឿងក្តីតែមួយគត់ ដែលការជម្លៀសឆ្លងព្រំដែនប្រទេសមួយមិនត្រូវបានចាត់ទុកជាលក្ខខណ្ឌនៃឧក្រិដ្ឋកម្មស្តីពីការនិរទេស)។ សូមមើលផងដែរ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Slobodan Milosevic,* សំណុំរឿង លេខ IT-02-54-T, សេចក្តីសម្រេចលើញត្តិពាក់ព័ន្ធនឹងសាលក្រមលើកលែងការចោទប្រកាន់ (អង្គជំនុំជម្រះសាលាដំបូង ICTY ), ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៤, កថាខណ្ឌ ៦៤។

[61] *Stakić*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ១៤ , កថាខណ្ឌ ៦៧៧, កថាខណ្ឌ ៦៧៨, កថាខណ្ឌ ៦៨០, កថាខណ្ឌ ៦៨៥។

[62] *Krajišnik*, សាលដីការបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៣០៨ (លុបចោលការទាញសំអាងខាងក្នុង)។ សូមមើលផងដែរ *Milosevic*, សេចក្តីសម្រេចរបស់ ICTY ស្តីពីការសម្រេចឱ្យរួចផុតពីបទចោទ, *ដូច*

បង្ខំពីទីកន្លែងមួយ ទៅទីកន្លែងមួយទៀតនៅក្នុងរដ្ឋតែមួយ"[64]។ វាមានលក្ខណៈខុសគ្នាពីឧក្រិដ្ឋកម្មដែលពាក់ព័ន្ធឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការនិរទេស ត្រង់តែចំណុចដែលថា លក្ខខណ្ឌនៃការនិរទេសតម្រូវឲ្យការផ្លាស់ទីលំនៅនោះត្រូវឆ្លងកាត់ព្រំដែន[65]។ ម្យ៉ាងវិញទៀត "ឧក្រិដ្ឋកម្មនៃការនិរទេស

---

*កំណត់សម្គាល់ខាងលើ* កថាខណ្ឌ ៦៨ (រកឃើញពីភាពខុសគ្នារវាងការជម្លៀសដោយបង្ខំ និងការនិរទេស នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ)។

[63] ពាក្យផ្សេងៗទៀតត្រូវបានប្រើនៅក្នុងឧក្រិដ្ឋកម្មនេះ រួមមានការជម្លៀសដោយបង្ខំ, ការបណ្តេញចេញពីលំនៅឋានដោយបង្ខំ, ការបំលាស់ទីលំនៅដោយបង្ខំ និងការជម្លៀសប្រជាជន។ *សូមមើល Blagoje Simić និងអ្នកផ្សេងទៀត,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៥៧, កថាខណ្ឌ ១២១, ជើងទំព័រ ២១១។

[64] Bassiouni, *ដូចខាងលើ* កំណត់សម្គាល់ ៣១, កថាខណ្ឌ ៣៨១។

[65] *សូមមើល* សេចក្តីសម្រេច ICTY ដោយធ្វើការកត់សម្គាល់ពីភាពខុសគ្នារវាងការនិរទេសដែលត្រូវឆ្លងព្រំដែនអន្តរជាតិ និងការជម្លៀសដោយបង្ខំ នៅក្នុងប្រទេស ៖ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង MIlomir Stakić*, សំណុំរឿង លេខ IT-97-24-T, សេចក្តីសម្រេចលើញត្តិដោយផ្អែកលើវិធាន ៩៨ ស្ទួន ពាក់ព័ន្ធនឹងសាលក្រមលើកលែងការចោទប្រកាន់ (អង្គជំនុំជម្រះសាលាដំបូង II របស់ ICTY), ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០២, កថាខណ្ឌ ១៣០; *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Momčilo Krajišnik*, សំណុំរឿង លេខ IT-00-39-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង I របស់ ICTY), ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦, កថាខណ្ឌ ៧២៣; *Blagojević និងអ្នកផ្សេងទៀត,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៥៩៥; *Krnojelac,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៣៣, កថាខណ្ឌ ៤៧៤, ៤៧៦, ជើងទំព័រ ១៤២៩; *Krstić,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៦៣, កថាខណ្ឌ ៥៣១ ដល់ ៥៣២; *Brđanin*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨ , កថាខណ្ឌ ៥៤០, កថាខណ្ឌ ៥៤៤; *Blagoje Simić និងអ្នកផ្សេងទៀត,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៥៧, កថាខណ្ឌ ១២២, កថាខណ្ឌ ១២៣។ សូមមើលផងដែរ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង João Sarmento*, សំណុំរឿង លេខ 18A/2001, សាលក្រម (ក្រុមពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរក្នុងស្រុក Dili), ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៣, កថាខណ្ឌ ៩៥ (ដោយធ្វើការពិភាក្សាពីភាពខុសគ្នានៃស្ថានភាពរបស់ជនភៀសខ្លួន ធៀបនឹងប្រជាជនដែលត្រូវបានជម្លៀសនៅក្នុងប្រទេស)។ សូមមើលផងដែរ បទអត្ថាធិប្បាយស្តីពីលក្ខខណ្ឌនៃការឆ្លងព្រំដែនអន្តរជាតិ ៖ Bassiouni, *ដូចខាងលើ* កំណត់សម្គាល់ ៣១, ទំព័រ ៣៨១; Kriangsak Kittichaisaree, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (ឆ្នាំ ២០០១), ទំព័រ ១០៩; Henckaerts, *ដូចខាងលើ* កំណត់សម្គាល់ ២៨, ទំព័រ ៤៧២; Christopher Hall, "មាត្រា ៧ ៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" នៅក្នុង Triffterer (ed) *បទអត្ថាធិប្បាយ ស្តីពីលក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់ តុលាការព្រហ្មទណ្ឌអន្តរជាតិ* (១៩៩៩), ទំព័រ ១៣៦។

និងការជម្លៀសដោយបង្ខំមានធាតុផ្សំដូចគ្នា លើកលែងតែទាក់ទិននឹងគោលដៅប៉ុណ្ណោះ[66]។ ដូច្នេះ ទោះបីជា "ទាំងការនិរទេស និងការជម្លៀសដោយបង្ខំ ពាក់ព័ន្ធនឹងការជម្លៀសបុគ្គលដោយខុសច្បាប់ និងដោយលក្ខណៈមិនស្ម័គ្រចិត្ត ចេញពីទឹកដីដែលពួកគេរស់នៅ... យ៉ាងណាក៏ដោយ ក៏ពាក្យពេចន៍ទាំងពីរនេះពុំមានន័យដូចគ្នាឡើយ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ការនិរទេស គឺជាការផ្លាស់ទីលំនៅចេញក្រៅពីព្រំដែនរបស់រដ្ឋមួយ ចំណែកឯការជម្លៀសដោយបង្ខំ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅនៅក្នុងរដ្ឋមួយ"[67]។ ទោះបីជាយ៉ាងណាក៏ដោយ "ការខុសគ្នានេះ ពុំមានឥទ្ធិពលទៅលើការថ្កោលទោសអំពីអំពើបែបនេះឡើយ នៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ"[68]។ ទោះបីជាមានការហាមឃាត់ចំពោះអំពើទាំងនេះយ៉ាងណាក៏ដោយ "ក៏ច្បាប់មនុស្សធម៌អន្តរជាតិទទួលស្គាល់កាលៈទេសៈដែលមានកម្រិត ដែលកាលៈទេសៈនេះអនុញ្ញាតឲ្យមានការផ្លាស់ទីលំនៅប្រជាជនស៊ីវិលយ៉ាងតឹងរ៉ឹងបំផុតក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ"[69]។

21. ធាតុផ្សំសត្យានុម័តនៃការផ្លាស់ទីលំនៅដោយបង្ខំគឺ ៖ (១) ការផ្លាស់ទីលំនៅរបស់បុគ្គលតាមរយៈការបណ្តេញ ឬអំពើបង្ខិតបង្ខំផ្សេងៗទៀត (២) ចេញពីតំបន់ ដែលពួកគេមានទីលំនៅត្រឹមត្រូវតាមច្បាប់ (៣)

[66] *Milosevic*,សេចក្តីសម្រេច ICTY ស្តីពីការលើកលែងការចោទប្រកាន់, *ដូចខាងលើ* កំណត់សម្គាល់ ៦៣, កថាខណ្ឌ ៧៩។

[67] *Krstić*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៦៣, កថាខណ្ឌ ៥២១។ សូមមើលផងដែរ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Dragan Nikolic, សំណុំរឿង លេខ IT-94-2-R61, ការពិនិត្យឡើងវិញលើដីកាចោទប្រកាន់ អនុលោមតាមវិធាន ៦១ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង (អង្គជំនុំជម្រះសាលាដំបូង ICTY), ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៥, កថាខណ្ឌ ២៣ (ការជម្លៀសអ្នកជាប់ឃុំឃាំងពីកន្លែងឃុំឃាំងមួយទៅកន្លែងឃុំឃាំងផ្សេងទៀត "អាចចាត់ទុកថាជាការជម្លៀសខ្លួន")។ សូមមើល *contra Krnojelac,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៣៣, កថាខណ្ឌ ៤៧៤, កថាខណ្ឌ ៤៧៨, និងជើងទំព័រ ១៤៣០។

[68] *Krstić,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៦៣, កថាខណ្ឌ ៥២២ (លុបចោលការទាញសំអាងខាងក្នុង)។

[69] *Krajišnik,* សាលដីការបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៣០៨ (លុបចោលការទាញសំអាងខាងក្នុង)។ សូមមើលផងដែរ *Milosevic,* សេចក្តីសម្រេច ICTY ស្តីពីការលើកលែងការចោទប្រកាន់, *ដូចកំណត់សម្គាល់ខាងលើ* កថាខណ្ឌ ៦៨។

ដោយគ្មានហេតុផលដែលអនុញ្ញាតនៅក្រោមច្បាប់អន្តរជាតិ[70]។ ការផ្លាស់ទីលំនៅមានលក្ខណៈមិនស្ម័គ្រចិត្ត។ ការនិរទេស ត្រូវបាន "បង្ខំ" ប្រសិនបើការប្រើប្រាស់កម្លាំង ឬការគំរាមកំហែងដោយប្រើកម្លាំង ឬប្រភេទផ្សេងៗទៀតនៃកាបង្ខិតបង្ខំ បង្កើតបានជាការជឿជាក់សមហេតុផលមួយថា ការខកខានមិនធ្វើការផ្លាស់ទីកន្លែងនឹងធ្វើឲ្យបុគ្គលមានគ្រោះថ្នាក់ធ្ងន់ធ្ងរថែមទៀត។ វាជាការខ្វះនូវ "ជម្រើសពិតប្រាកដ" ដែលធ្វើឲ្យអំពើនៃការផ្លាស់ទីលំនៅនោះខុសច្បាប់[71]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងនៅតុលាការ ICTY បានបញ្ជាក់៖ "វាសំខាន់ណាស់ សម្រាប់ទាំង "ការនិរទេស" និង "ការជម្លៀសដោយបង្ខំ" ដែលការផ្លាស់ទីលំនៅកើតឡើង ក្រោមការបង្ខិតបង្ខំ។ ធាតុផ្សំសំខាន់នៅក្នុងការបង្កើតឲ្យមានការបង្ខិតបង្ខំគឺថា ការ

[70] *Brđanin*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៥៤០; *Blagoje Simić និងអ្នកផ្សេងទៀត,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៥៧, កថាខណ្ឌ ១២៤។ សូមមើលផងដែរ Bassiouni, *ដូចខាងលើ* កំណត់សម្គាល់ ៣១, កថាខណ្ឌ ៣៩៥ (បង្ហាញពីបញ្ជីធាតុផ្សំនៃការនិរទេស ឬការជម្លៀសដោយបង្ខំដែលត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ)។

[71] សូមមើលបទអត្ថាធិប្បាយ Bassiouni, *ដូចខាងលើ* កំណត់សម្គាល់ ៣១, ទំព័រ៣៩៣; Antonio Cassese (ed.), *The Oxford Companion to International Criminal Justice* (២០០៩), ទំព័រ ២៩៦; Clair de Than and Edward Shorts, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងសិទ្ធិមនុស្ស* (២០០៣), ទំព័រ ១០១។ សូមមើល សេចក្តីសម្រេច ICTY ដែលបានធ្វើការកត់សម្គាល់ពីនិយមន័យទូលំទូលាយនៃការបង្ខិតបង្ខំសម្រាប់ជម្លៀសខុសច្បាប់ដោយមិនកម្រិតត្រឹមតែការបង្ខិតបង្ខំខាងរាងកាយប៉ុណ្ណោះទេ តែរួមទាំងការគំរាមកំហែង, ការឃុំឃាំង, ការគាបសង្កត់ផ្លូវចិត្ត, ការគាបសង្កត់, បរិយាកាសគាបសង្កត់ ឬស្ថានភាពណាមួយដែលពុំមានជម្រើសអ្វីសោះ បើទោះបីជាមានការឯកភាពច្បាស់លាស់ ឬផ្លូវការក៏ដោយ ៖ *Stakić*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ១៤, កថាខណ្ឌ ៦៨២; *Blagojević និងអ្នកផ្សេងទៀត,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៥៩៦; *Brđanin*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៥៤៣, កថាខណ្ឌ ៥៤៩; *Krstić,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៦៣ , កថាខណ្ឌ ៥២៩, កថាខណ្ឌ ៥៣០; *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Mladen Naletilic *និងអ្នកផ្សេងទៀត,* សំណុំរឿង លេខ IT-98-34-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង ICTY), ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣, កថាខណ្ឌ ៥១៩; *Blagoje Simić និងអ្នកផ្សេងទៀត,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៥៧, កថាខណ្ឌ ១២៥, កថាខណ្ឌ ១២៦, កថាខណ្ឌ ១២៨; *Krajišnik*, សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៣១៩; *Krnojelac,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៣៣, កថាខណ្ឌ ៤៧៥។ សូមមើលផងដែរ *Sarmento*, សាលក្រម SPSC, *ដូចខាងលើ* កំណត់សម្គាល់ ៧៣, កថាខណ្ឌ ១០៣។

ផ្លាស់ទីលំនៅ ត្រូវមានលក្ខណៈមិនស្ម័គ្រចិត្ត ដែលបុគ្គលពាក់ព័ន្ធនោះពុំមានជម្រើសពិតប្រាកដ។ លើសពីនេះទៀត ការផ្លាស់ទីលំនៅត្រូវតែខុសច្បាប់”[72]។

22. ធាតុផ្សំអត្តនោម័តសម្រាប់បទល្មើសនេះ គឺចេតនាក្នុងការផ្លាស់ទីកន្លែង(ដោយអចិន្ត្រៃយ៍ ឬម្យ៉ាងទៀតដោយយថាហេតុ) ជនរងគ្រោះស្ថិតនៅក្នុងព្រំដែនជាតិពាក់ព័ន្ធ[73] នេះបញ្ចូលចេតនាទាំងពីនេះ(*ចេតនាទុច្ចរិតផ្ទាល់ នៅក្នុងកម្រិតទី១ និងទី២*) និងការធ្វេសប្រហែសប្រយោល(ចេតនាទុច្ចរិតប្រយោល)[74]។

---

[72] *Brđanin*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៥៤៣; *Blagoje Simić និងអ្នកផ្សេងទៀត*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៥៧, កថាខណ្ឌ ១២៥។ សូមមើលផងដែរ *Naletilic,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨០, កថាខណ្ឌ ៥២១។

[73] *Naletilic,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨០, កថាខណ្ឌ ៥៣៦ ដល់ ៥៣៧ (ការចាត់ទុកការជម្លៀសត្រឹមតែជាការឃុំឃាំង ជាជាងគោលបំណងនៃការជម្លៀស មិនមែនជារឿងមិនស្របច្បាប់នោះទេ ពីព្រោះលក្ខខណ្ឌនៃចេតនាឧក្រិដ្ឋមិនត្រូវបានបំពេញនោះទេ)។

[74] សហចៅក្រមស៊ើបអង្កេតបានរកឃើញថា ជាចុងក្រោយ ប្រជាជនទាំងអស់ដែលត្រូវបានចោទថារងការជម្លៀសដោយបង្ខំនោះ មិនអាចត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ “បន្ទាប់ពីការដួលរលំនៃរបបនេះ” (ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤៦៤)។ យុត្តិសាស្ត្រដែលថាតើគោលបំណងគឺជាចេតនានៃការផ្លាស់ទីលំនៅជាអចិន្ត្រៃយ៍ និងថាតើការវិលត្រឡប់របស់ជនរងគ្រោះនៅចុងក្រោយ មានឥទ្ធិពលដល់ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ យ៉ាងណានោះ, គឺជាយុត្តិសាស្ត្រដែលនៅមិនទាន់បានដោះស្រាយនៅឡើយទេ ៖ ចំពោះគោលជំហរដែលថា ចេតនាមិនតម្រូវឱ្យមានការផ្លាស់ទីលំនៅជាអចិន្ត្រៃយ៍ សូមមើល *Stakić,* សាលដីការបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨ , កថាខណ្ឌ ៣០, កថាខណ្ឌ ៣០៦; *Krajišnik,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៧៣, កថាខណ្ឌ ៧២៦; Bassiouni, *ដូចខាងលើ* កំណត់សម្គាល់ ៣១, កថាខណ្ឌ ៣៩៣។ ចំពោះគំនិតនេះ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ សុទ្ធតែត្រូវមានគោលបំណងនៃការផ្លាស់ទីលំនៅជាអចិន្ត្រៃយ៍ សូមមើល *Stakić,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ១៤ , កថាខណ្ឌ ៦៨៦ ដល់ ៦៨៧; *Blagoje Simić និងអ្នកផ្សេងទៀត,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៥៧, កថាខណ្ឌ ១៣២, កថាខណ្ឌ ១៣៤, កថាខណ្ឌ ៩៧៤ (With regards to intent, អង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សម្គាល់ទាក់ទងនឹងគោលបំណងថា បទអត្ថាធិប្បាយ ICRC នៅក្នុងអនុសញ្ញាក្រុងហ្សឺណែវ IV រួមទាំងអង្គជំនុំជម្រះមុនៗ តម្រូវថា ការជម្លៀសត្រូវតែជាការជម្លៀសអចិន្ត្រៃយ៍); Cassese, *ដូចខាងលើ* កំណត់សម្គាល់ ៨០, ទំព័រ ២៩៦។ ថាតើជនរងគ្រោះវិលត្រឡប់ទៅវិញដោយឆន្ទៈរបស់ខ្លួនផ្ទាល់ ឬយ៉ាងណានោះ ពុំមានឥទ្ធិពលលើការទទួលខុសត្រូវខាងព្រហ្មទណ្ឌពាក់ព័ន្ធនឹងចេតនានោះឡើយ។ សូមមើល *Blagojević និងអ្នកផ្សេងទៀត,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៥៩៦; *Brđanin*, សាលក្រម

នៅក្នុងរឿងក្តី *Milošević* រដ្ឋអាជ្ញាសន្និដ្ឋានថា“ទាំងអស់តម្រូវថាចារីប្រព្រឹត្តដោយដឹងអំពីភវនីយភាពច្រើនដែលនេះអាចកើតឡើងដូចជាផលនៃអំពើរបស់ចារី”[75]។ ទោះបីជាមានបែបនេះក៏ដោយ អង្គជំនុំជម្រះតុលាការ ICTY បានសម្រេចថា ធាតុផ្សំអត្តនោម័តតឹងរ៉ឹងតិចជាងនេះអាចអនុវត្តបាន ដោយបញ្ជាក់ថា “ត្រូវតែបង្ហាញថាចារីមានចេតនាដោយផ្ទាល់ត្រង់ថាជនរងគ្រោះអាចគេចផុត ឬត្រង់ថាអាចព្យាករបានពីអំពើដែលអាចកើតចេញ”[76]។

23. ពុំមានពាក់ព័ន្ធជាមួយនឹងចំនួនបុគ្គលជាអប្បបរមា ដែលត្រូវទទួលរងផលប៉ះពាល់ដោយការជម្លៀសដោយបង្ខំ ដើម្បីភ្ជាប់ការទទួលខុសត្រូវនោះឡើយ[77]។

*iv.* *<u>មូលដ្ឋានដែលអាចអនុញ្ញាតបានចំពោះការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ</u>*

24. ដូចដែលមានចែងនៅក្នុងមាត្រា៤៩នៃអនុសញ្ញាទីក្រុងហ្សឺណែវទីបួនថា[78]៖

> ***ការជម្លៀសបុគ្គល ឬមហាជនដោយបង្ខំ ត្រូវបានហាមឃាត់ ដោយមិនគិតដល់ ហេតុផលនៃការជម្លៀសឡើយ។*** *ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋកំពុងកាន់កាប់អំណាច****អាចទទួលយកការជម្លៀសមួយផ្នែក ឬទាំងអស់នៃតំបន់ដែលបានផ្តល់ឱ្យ ប្រសិនបើសន្តិសុខរបស់ប្រជាជន ឬហេតុផលយោធាទាមទារឱ្យមានដូច្នេះ។ បុគ្គលដែលត្រូវបានជម្លៀសនឹងត្រូវបានបញ្ជូនទៅកាន់ស្រុកកំណើតរបស់គេវិញឱ្យបានឆាប់ នៅពេលដែល អំពើអរិភាពនៅក្នុងតំបន់នោះត្រូវបានចប់***[79] ។

របស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨ , កថាខណ្ឌ ៥៤៥, កថាខណ្ឌ ៥៥៥, កថាខណ្ឌ ៦០១; *Naletilic,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨០, កថាខណ្ឌ ៥២០; *Stakić*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ១៤ , កថាខណ្ឌ ៦៨៦, ៦៨៧។

[75] *Milosevic*, សេចក្តីសម្រេច ICTY ស្តីពីការលើកលែងការចោទប្រកាន់, *ដូចខាងលើ* កំណត់សម្គាល់ ៦៨, កថាខណ្ឌ ៧៨។

[76] ដូចកំណត់សម្គាល់ខាងលើ ត្រង់កថាខណ្ឌទី៧៨។

[77] *Stakić*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ១៤, កថាខណ្ឌ ៦៨៥។

[78] Henckaerts, *ដូចខាងលើ* កំណត់សម្គាល់ ២៨, ទំព័រទី៤៧១ (“យោងមាត្រា៤៩ជាបទប្បញ្ញត្តិគន្លឹះ”)

[79] មាត្រា ៤៩.២ នៃអនុសញ្ញាទីក្រុងហ្សឺណែវទីIV និងទាំងមាត្រា ១៧.១ នៃពិធីសារបន្ថែមទីII មានបទប្បញ្ញត្តិដែលចែងពីករណីលើកលែង កាលណា “មានជាប់ទាក់ទងនឹងសន្តិសុខរបស់ជនស៊ីវិល ឬ មានការទាមទារយ៉ាងខ្លាំងនូវមូលហេតុដាច់ខាតខាងយោធា”, ករណី Cassese,

25. សេចក្តីអត្ថាធិប្បាយចំពោះមាត្រា៤៩ សង្កត់ធ្ងន់ថា *ពុំមានមូលដ្ឋានលើកលែងណាផ្សេងទៀត* ដែលត្រូវអនុញ្ញាតឡើយ[80]។ អង្គជំនុំជម្រះរបស់តុលាការ ICTY និងតុលាការដែលមានចរិតលក្ខណៈជាតុលាការអន្តរជាតូបនីយកម្មដទៃទៀតបានអះអាងថា ករណីលើកលែងដែលអាចអនុញ្ញាតបាន ត្រូវបានកំណត់ត្រឹមមូលដ្ឋានទាំងនេះ[81] ដូចដែលលិខិតុបករណ៍គតិយុត្តិអន្តរជាតិថ្មីៗនេះបានបញ្ជាក់[82]។

26. ប្រការនេះគឺជាក្តីបារម្ភចំពោះការកំណត់ចំៗ មិនត្រឹមតែចំពោះមូលដ្ឋាននៃករណីលើកលែងដែលអាចអនុញ្ញាត

កំណត់សម្គាល់*ខាងលើ*លេខ៨០ ត្រង់ទំព័រទី ២៩៥។ អនុសញ្ញាទីក្រុងហ្សឺណែវទីIV, កំណត់សម្គាល់*ខាងលើ*លេខ២៤ ត្រង់មាត្រា ៤៩.២។ សូមអានផងដែរ *Blagoje Simic និងគូកន,* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, កំណត់សម្គាល់*ខាងលើ*លេខ៥៧ ត្រង់កថាខណ្ឌទី ១២៧។ ករណី Henckaerts, កំណត់សម្គាល់*ខាងលើ*លេខ២៨ ត្រង់ទំព័រទី ៤៧៣។

[80] អនុសញ្ញាក្រុងហ្សឺណែវទីបួន, *ដូចខាងលើ* បទអត្ថាធិបាយលើកំណត់សម្គាល់ ២៤, មាត្រា ៤៩។

[81] *Krstić,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៦៣, កថាខណ្ឌ ៥២៤, ជើងទំព័រ ១១៧៥; *Naletilic,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨០, កថាខណ្ឌ ៥១៨; *Sarmento*, សាលក្រម SPSC, *ដូចខាងលើ*កំណត់សម្គាល់ ៧៣ , កថាខណ្ឌ ១០២, កថាខណ្ឌ ១០៥។

[82] ករណីលើកលែងដែលអាចទទួលយកបានមួយចំនួនក៏ត្រូវបានយកមកឆ្លុះបញ្ចាំងនៅក្នុងឯកសារមួយចំនួននាពេលថ្មីៗនេះ ទាំងនៅក្នុងឯកសារបរទេស ទាំងឯកសារក្នុងប្រទេស។ សូមមើល កិច្ចព្រមព្រៀងលម្អិតស្តីពីការគោរពសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិ (IHL) ក្នុងប្រទេសហ្វីលីពីន, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៩៨, មាត្រា ៣(៧); កិច្ចព្រមព្រៀង ឆ្នាំ ១៩៩២ ស្តីពីការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិរវាងភាគីទាំងអស់ក្នុងជម្លោះនៅបូស្នី និងហ៊ើសេហ្គូវីណា, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩២, កថាខណ្ឌ ២.៣; បទប្បញ្ញត្តិ UNTAET លេខ ២០០០/១៥ ស្តីពីការបង្កើតក្រុមដែលមានសមត្ថកិច្ចផ្តាច់មុខលើបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ, ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០០, ផ្នែក ៦(១)(ក) (vii), ផ្នែក ៦(១)(ង) (viii); គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស, បទដ្ឋានមនុស្សធម៌អប្បបរមា, ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ១៩៩៥, មាត្រា ៧; កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR), *ដូចខាងលើ* កំណត់សម្គាល់ ៥០, មាត្រា ១២; សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR), *ដូចខាងលើ* កំណត់សម្គាល់ ៥០, មាត្រា ១៣; អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ ៦៦០ U.N.T.S. ១៩៥, ថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៦៩, មាត្រា ៥; អនុគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស, *សិទ្ធិមនុស្ស និងការជម្លៀសប្រជាជន, ឧបសម្ព័ន្ធ II ៖ សេចក្តីព្រាងនៃសេចក្តីប្រកាសស្តីពីការជម្លៀសប្រជាជន និងការបញ្ចូលអ្នកតាំងទីលំនៅ,* ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៧, មាត្រា ៤។

បានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះកាលៈទេសៈដែលមូលដ្ឋាននានាដែលអាចអនុញ្ញាតបាន អាចត្រូវបានយកមកអនុវត្តផងដែរ ដែលមាត្រា៤៩នេះ ដាក់បញ្ចូលនៅក្នុងបទប្បញ្ញត្តិនូវការកម្រិតមួយចំនួនលើករណីលើកលែងទាំងនេះ។ ដូចដែលអ្នកធ្វើអត្ថាធិប្បាយមួយរូបបានសង្ខេប ទោះបីជានៅពេលដែលការជម្លៀសអាចអនុញ្ញាតបាន សម្រាប់សន្តិសុខរបស់ប្រជាជន ឬមូលហេតុយោធាជាសំខាន់យ៉ាងណាក៏ដោយ ក៏ការជម្លៀសនេះនៅតែស្ថិតនៅក្រោមលក្ខខណ្ឌមួយចំនួន៖

> *ទីមួយ ការផ្លាស់ទីកន្លែងមិនត្រូវបានអនុញ្ញាតឡើយ នៅក្រៅព្រំដែនទឹកដីរបស់រដ្ឋដែលត្រូវបានត្រួតត្រា លើកលែងតែមិនអាចជៀសវាងបាន "ដោយសារហេតុផលសំខាន់ចាំបាច់"។ ទីពីរ នៅពេលដែលអរិភាពត្រូវបានបញ្ចប់ អ្នកដែលត្រូវបានជម្លៀសគួរតែត្រូវបានបញ្ជូនត្រឡប់មកភូមិកំណើតវិញ។ ទីបី រដ្ឋដែលកំពុងកាន់កាប់អំណាចត្រូវបានតម្រូវឲ្យផ្ដល់នូវកន្លែងស្នាក់នៅសមរម្យ "ក្នុងកម្រិតដែលអាចធ្វើទៅបាន" ជូនទៅដល់អ្នកទាំងឡាយដែលត្រូវបានជម្លៀស ហើយការជម្លៀសគួរតែត្រូវបានអនុវត្ត "នៅក្នុងលក្ខខណ្ឌល្អទទួលយកបានចំពោះអនាម័យ សុខភាព សុវត្ថិភាព និងចំណីអាហារ"។ ទីបួន សមាជិកគ្រួសារមិនគួរត្រូវបានបំបែកចេញពីគ្នាឡើយ ហើយចុងក្រោយ រដ្ឋអាណាព្យាបាលគួរតែត្រូវបានជូនដំណឹងអំពីការផ្លាស់ទីកន្លែងនេះ*[83] ។

27. ដោយផ្អែកលើមូលដ្ឋាននេះ គណៈកម្មការពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរបានសម្រេចថា "បទដ្ឋានគឺដូចគ្នាសម្រាប់ជម្លោះក្នុងស្រុក និងជម្លោះអន្តរជាតិ៖ ប្រសិនបើជនស៊ីវិលត្រូវបានផ្លាស់ទីកន្លែងដោយសារតែហេតុផលណាមួយក្នុងចំណោមហេតុផលទាំងពីរនេះ គឺហេតុផលសុវត្ថិភាព និងហេតុផលចាំបាច់បំផុតផ្នែកយោធានោះ ការជម្លៀសត្រូវតែស្ថិតនៅក្រោមលក្ខខណ្ឌមនុស្សធម៌ អនាម័យ និងត្រូវបានការពារមានរយៈ

---

[83] Emily Haslam, "ប្រជាជន, ការបង្ខិតបង្ខំ និងការជម្លៀស" នៅក្នុង *Max Planck Encyclopedia of Public International Law ២០១២ (សព្វវចនាធិប្បាយផ្នែកច្បាប់សាធារណៈអន្តរជាតិ ដែលរៀបរៀងដោយ Max Planck*) កថាខណ្ឌ ២០ (លុបចោលការទាញសំអាងខាងក្នុង)។ សូមមើលផងដែរ *Naletilic,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨០, កថាខណ្ឌ ៥១៩, ជើងទំព័រ ១៣៥៧។

ពេលខ្លីបំផុតតាមដែលអាចធ្វើទៅបាន"[84]។ លើសពីនេះទៀត "នៅក្នុងករណីនីមួយៗ ត្រូវតែមានអត្ថិភាពនៃភាពចាំបាច់ពិតប្រាកដ។ វិធានការនានាដែលអនុវត្ត មិនមែនគ្រាន់តែជាការបង្កព្យសនកម្មតាមតែទំនើងចិត្ត ឬមានចេតនាគ្រាន់តែបម្រើឱ្យផលប្រយោជន៍ត្រឹមកម្រិតណាមួយរបស់រដ្ឋដែលកំពុងកាន់កាប់អំណាចនោះឡើយ"[85]។

28. វាសំខាន់ណាស់ក្នុងការកត់សម្គាល់ថា នៅពេលដែលធ្វើឡើងដោយផ្អែកលើមូលដ្ឋានដែលអាចអនុញ្ញាត ការផ្លាស់ទីកន្លែងគឺជាសកម្មភាពមួយខុសគ្នាពីការជម្លៀសដោយបង្ខំទាំងស្រុងតាមផ្លូវច្បាប់ — វាជា "ការជម្លៀស" "ដែលតាមនិយមន័យគឺជាវិធានការរយៈពេលខ្លី និងបណ្ដោះអាសន្ន"[86]។ "ការជម្លៀសពិតប្រាកដ ដូចដែលមានចែងនៅក្នុងមាត្រា៤៩ បង្កើតបានជាយុត្តិកម្មពិសេសសម្រាប់ការនិរទេស ឬការជម្លៀសជនស៊ីវិលរបស់សត្រូវ។ ភាពខុសគ្នានេះគឺ មានលក្ខណៈសមហេតុផល ដោយសារតែគោលបំណងរបស់វាត្រូវគ្នាជាមួយនឹងគោលបំណងនៃការហាមឃាត់ជាមូលដ្ឋាននៃមាត្រា៤៩ ហើយពិតណាស់គោលបំណងនៃអនុសញ្ញាទីក្រុងហ្សឺណែវ IV ទាំងមូល ពោល គឺការពារជនស៊ីវិល"[87]។ ជាលទ្ធផលទោះបីជាធ្វើឡើងដោយសារមូលហេតុសន្តិសុខរបស់ប្រជាជនស៊ីវិល ឬដោយមូលហេតុចាំបាច់បំផុតផ្នែកយោធាក៏ដោយ ការផ្លាស់ទីកន្លែងដែលអាចអនុញ្ញាតបានត្រូវបានកំណត់ផ្នែកខ្លះដោយកាលៈទេសៈដែលថា "ដូច្នេះ បុគ្គលដែលត្រូវបានជម្លៀស ត្រូវបានបញ្ជូនត្រឡប់ទៅភូមិកំណើតរបស់ពួកគេវិញឱ្យបានឆាប់នៅ

[84] *Sarmento*, សាលក្រម SPSC, *ដូចខាងលើ* កំណត់សម្គាល់ ៧៣, កថាខណ្ឌ ៩៩។

[85] *បទអត្ថាធិប្បាយ ICRC ស្ដីពីអនុសញ្ញាក្រុងហ្សឺណែវទីបួន, ដូចខាងលើ* កំណត់សម្គាល់ ១០, ទំព័រ ២៨១ (ផ្ដល់យោបល់លើសំអាងហេតុដែលអាចទទួលយកបានចំនួនពីរក្នុងការហាមឃាត់សិទ្ធិរបស់ជនទទួលបានការការពារក្នុងការចេញពីកន្លែងមួយទៅកន្លែងមួយទៀតឡើយ)។

[86] *Stakić*, សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ២៨៤; *Blagojević និងអ្នកផ្សេងទៀត*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៥៩៧ ដល់ ៥៩៨។ សូមមើលផងដែរ *បទអត្ថាធិប្បាយ ICRC ស្ដីពីអនុសញ្ញាក្រុងហ្សឺណែវទីបួន, ដូចខាងលើ* កំណត់សម្គាល់ ១០, ទំព័រ ២៨០។

[87] Henckaerts, *ដូចខាងលើ* កំណត់សម្គាល់ ២៨, ទំព័រ ៤៧៣។

ពេលដែលអរិភាពនៅក្នុងតំបន់នោះបានបញ្ចប់"[88]។ លក្ខខណ្ឌតម្រូវក្នុងការសម្រួលដល់ការវិលត្រឡប់មកវិញនេះ អាចមានលក្ខណៈកាន់តែឆាប់រហ័ស ជាងលក្ខខណ្ឌតម្រូវនៃការធ្វើមាតុភូមិនិវត្តន៍ផ្សេងទៀត ដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ៖ "ជនស៊ីវិលដែលត្រូវបានជម្លៀស ត្រូវបានធ្វើមាតុភូមិនិវត្តន៍ភ្លាមៗ នៅក្នុងស្ថានភាពណាក៏ដោយ នៅពេលដែលអរិភាពនៅក្នុងតំបន់នោះបានបញ្ចប់។ ជាលទ្ធផលមិនដូចជាការធ្វើមាតុភូមិនិវត្តន៍ចំពោះឈ្លើយសឹកឡើយ ការធ្វើមាតុភូមិនិវត្តន៍នៃអ្នកដែលត្រូវបានជម្លៀសអាចត្រូវបានធ្វើឡើងនៅមុនពេលបញ្ចប់អរិភាពទាំងអស់"[89]។ នៅពេលដែលជនស៊ីវិលមិនត្រូវបានបញ្ជូនត្រឡប់ទៅភូមិកំណើតរបស់គេវិញឱ្យបានឆាប់ នៅពេលដែលអរិភាពនៅក្នុងតំបន់នោះបានបញ្ចប់ ឬយុត្តិកម្មចំពោះការជម្លៀស ពុំមានអត្ថិភាពតទៅទៀតនោះទេ ប្រការនេះអាចបង្ហាញថា យុត្តិកម្មដែលបានផ្តល់ជូននោះគឺគ្រាន់តែជាលេសប៉ុណ្ណោះ[90]។ លើសពីនេះទៀត លក្ខខណ្ឌតម្រូវក្នុងការអនុញ្ញាតឱ្យមានការវិលត្រឡប់មកវិញនៃជនស៊ីវិលដែលត្រូវបានជម្លៀសនោះ គឺមានលក្ខណៈខ្លាំងសម្បើមណាស់ សូម្បីតែនៅពេលដែលការជម្លៀស ត្រូវបានអនុវត្តដោយផ្អែកលើមូលដ្ឋានដែលអាចអនុញ្ញាតបានក៏ដោយ ក៏ការជម្លៀសនោះក្លាយជាការជម្លៀសខុសច្បាប់ ប្រសិនបើប្រជាជនមិនត្រូវបានអនុញ្ញាតឱ្យវិលត្រឡប់មកវិញភ្លាមៗតាមដែលអាចធ្វើទៅបាននោះ[91]។

29. នៅពេលដែលអាជ្ញាធរដែលបង្ខំឱ្យមានការជម្លៀសប្រជាជនចាត់វិធានការនានា ដែលនឹងរារាំងមិនឱ្យមានការវិលត្រឡប់ ឬប្រឆាំងទៅនឹងការវិលត្រឡប់របស់ប្រជាជន ប្រការនេះបង្ហាញថា ធាតុផ្សំអត្តនោម័តនៃ

---

[88] Bassiouni, *ដូចខាងលើ* កំណត់សម្គាល់ ៣១, ទំព័រ ៣៩៥; *Krstić,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៦៣, កថាខណ្ឌ ៥២៤។

[89] Henckaerts, *ដូចខាងលើ* កំណត់សម្គាល់ ២៨, ទំព័រ ៤៧៥។

[90] *Krstić,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៦៣, កថាខណ្ឌ ៥២៥; *Brđanin*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៥៥៦; *Blagojević និងអ្នកផ្សេងទៀត,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៦០១; *បទអត្ថាធិប្បាយ ICRC ស្តីពីអនុសញ្ញាក្រុងហ្សឺណែវទីបួន*, *ដូចខាងលើ* កំណត់សម្គាល់ ១០, ទំព័រ ២៨០ ដល់ ២៨១។

[91] Than & Shorts, *ដូចខាងលើ* កំណត់សម្គាល់ ៨០, ទំព័រ ១០០; សូមមើលផងដែរ *Krajišnik,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៧៣, កថាខណ្ឌ ៧២៥។

ការជម្លៀសដោយបង្ខំគឺត្រូវបានបំពេញ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បាន កត់សម្គាល់៖ "នៅពេលដែលការជម្លៀសពិតប្រាកដកើតមានឡើង នោះមានកាតព្វកិច្ចមួយក្នុងការនាំយកប្រជាជនត្រឡប់មកវិញនៅពេលដែលអរិភាពបានបញ្ចប់។ ពុំមានការខិតខំប្រឹងប្រែងដើម្បីបញ្ជូនជនរងគ្រោះ ត្រឡប់មកវិញឡើយ។ តាមពិត ផ្ទះសម្បែងភាគច្រើនរបស់ពួកគេ ត្រូវបានដុតបំផ្លាញចោល នៅក្រោយ [ថ្ងៃដែលពួកគេត្រូវបានប្រមូលផ្តុំ]"[92]។ ដូចគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានកត់សម្គាល់ថា "ផ្ទះសម្បែងរបស់ជនរងគ្រោះ ទីកន្លែងធ្វើជំនួញរបស់ពួកគេ និងអគារសាសនារបស់ពួកគេត្រូវបានបំផ្លាញចោល" ហើយថា ទ្រព្យសម្បត្តិរបស់ពួកគេ ត្រូវបានរឹបអូសយក ឬត្រូវបានបង្ខំឱ្យបោះបង់ចោល ដោយគ្មានសំណងអ្វីទាំងអស់[93]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា ពុំមានមន្ទិលឡើយថា នៅក្នុងចិត្តគំនិតរបស់អាជ្ញាធរបូស្នី-ស៊ែប យុទ្ធនាការបោសសម្អាតជនជាតិភាគតិច អាចមានជោគជ័យ ប្រសិនបើជនជាតិម៉ូស្លីមបូស្នី និងជនជាតិក្រូអាតបូស្នី ត្រូវបានបណ្តេញចេញ*ជាអចិន្ត្រៃយ៍*"[94]។

30. សូម្បីតែយុត្តិកម្មដែលអាចទទួលយកបានចំពោះការជម្លៀសប្រជាជន អាចអនុញ្ញាតបាន តែនៅក្នុងកាលៈទេសៈតឹងរ៉ឹង និងចង្អៀតបំផុតប៉ុណ្ណោះ។ "ដោយពិចារណាទៅលើលក្ខណៈតឹងរ៉ឹងនៃការផ្លាស់ទីបុគ្គលដោយបង្ខំ ឧបាស្រ័យចំពោះវិធានការបែបនេះ នឹងមានលក្ខណៈត្រឹមត្រូវតាមច្បាប់តែនៅក្នុង កាលៈទេសៈធ្ងន់ធ្ងរបំផុតប៉ុណ្ណោះ និងជាវិធានការនៃដំណោះស្រាយចុងក្រោយប៉ុណ្ណោះ"[95]។ សេចក្តីអត្ថាធិប្បាយលើមាត្រា ៤៩ សង្កត់ធ្ងន់បន្ថែមទៀតលើការបកស្រាយយ៉ាងតឹងរ៉ឹងនៃករណីលើកលែង[96]។

---

[92] *Naletilic,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨០, កថាខណ្ឌ ៥២៦។

[93] *Brđanin*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៥៥៥។

[94] *ដូចខាងលើ*

[95] *Blagoje Simić និងអ្នកផ្សេងទៀត,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៥៧, កថាខណ្ឌ ១២៥, ជើងទំព័រ ៥២៦។

[96] *បទអត្ថាធិប្បាយ ICRC ស្តីពីអនុសញ្ញាក្រុងហ្សឺណែវទីបួន, ដូចខាងលើ* កំណត់សម្គាល់ ១០, ទំព័រ ២៨០។

31. ស្រដៀងគ្នានេះដែរ វាជាការខុសច្បាប់ក្នុងការប្រើប្រាស់វិធានការជម្លៀសប្រជាជនជាលេសមួយ ដើម្បីផ្លាស់ប្រជាជន និងរឹបអូសយកទឹកដី[97]។ លេសអាចត្រូវបានបង្ហាញឱ្យឃើញតាមរយៈលក្ខណៈសាហាវព្រៃផ្សៃដែលការជម្លៀសត្រូវបានធ្វើឡើង។[98]

32. ការជម្លៀសប្រជាជនដោយផ្អែកទៅលើភាពចាំបាច់ដើម្បីធានានូវសន្តិសុខរបស់ប្រជាជន នឹងបង្ហាញឱ្យឃើញអំពីលេសផងដែរ នៅពេលដែល "អរិភាពដ៏សកម្ម" នៅក្នុងតំបន់ដែលជនស៊ីវិលត្រូវបានបញ្ជូនចេញបានបញ្ចប់នៅត្រឹមពេលដែលមានការជម្លៀសនោះ[99]។ លើសពីនេះទៀត ការផ្លាស់ដោយហេតុផលមនុស្សធម៌ "មិនអាចធ្វើយុត្តិកម្មបានឡើយ អនុលោមតាមច្បាប់អន្តរជាតិ នៅពេលដែលវិបត្តិផ្នែកមនុស្សធម៌ដែលបានបណ្តាលឱ្យមានការផ្លាស់នោះ គឺជាលទ្ធផលនៃសកម្មភាពខុសច្បាប់ដោយផ្ទាល់ខ្លួនរបស់ជនជាប់ចោទ"[100]។

33. អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានរកឃើញការជម្លៀស ដែលបានផ្តល់យុត្តិកម្មដោយផ្អែកលើមូលដ្ឋានដែលថា វាចាំបាច់ដើម្បីធានានូវសុវត្ថិភាពរបស់ប្រជាជន នៅក្នុងសេណារីយ៉ូអង្គហេតុដែលមានកំណត់តែមួយប៉ុណ្ណោះ[101]។

---

[97] Bassiouni, *ដូចខាងលើ* កំណត់សម្គាល់ ៣១, ទំព័រ ៣៩៤។

[98] *Krstić,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៦៣, កថាខណ្ឌ ៥២៧។

[99] *ដូចខាងលើ,* កថាខណ្ឌ ៥២៥។

[100] *Krajišnik,* សាលដីការបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៣០៨, ជើងទំព័រ ៧៣៩។

[101] *Brđanin*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៥៥៦, ជើងទំព័រ ១៤២២ (បន្ទាប់ពីមានការវាយជាច្រើនដងលើភូមិនានារបស់បូស្នី ក្រូអាត និងបូស្នីឥស្លាមរួចមក, ប្រជាជនបូស្នីឥស្លាម និងបូស្នីក្រូអាតមួយក្រុមប្រមាណជា ៥០០ នាក់ ស្នើសុំនគរបាលយោធាស៊ីបបូស្នីដើម្បីសុំចេញពី Čelinac។ ដំបូង ក្រុមនេះត្រូវបានគេប្រាប់តម្រង់ផ្លូវដើម្បីចាកចេញពី ប៉ុន្តែដោយសារតែហេតុផលសន្តិសុខ មានការបញ្ជាមិនឱ្យប្រជាជនទាំងនេះចាកចេញពីតំបន់នេះឡើយ ហើយជនជាប់ចោទត្រូវបានគេបញ្ជាឱ្យយករថយន្តដឹកប្រជាជនទាំងនោះទៅដាក់នៅសាលាមតេយ្យមួយអស់រយៈពេលពី ៧ ទៅ ១៥ ថ្ងៃ ដោយមានការការពារពីគ្រោះថ្នាក់ និងការសងសឹក។ ប្រជាជនទាំងនេះបានត្រឡប់ទៅលំនៅឋានរបស់ខ្លួនវិញ បន្ទាប់ពីបានដោះលែង។

34. យុត្តិកម្មមួយដែលផ្អែកទៅលើភាពចាំបាច់ផ្នែកយោធា នឹងបង្ហាញឱ្យឃើញផងដែរនូវលេស នៅពេលដែលពុំមានការលេចចេញជាក់ស្តែងនៃការគំរាមកំហែងផ្នែកយោធានោះ[102] និងនៅពេលដែលសកម្មភាពដទៃទៀតរបស់អាជ្ញាធរ មិនបានបង្ហាញឱ្យឃើញនូវភាពចាំបាច់ផ្នែកយោធាដូចគ្នានេះ[103]។ លើសពីនេះទៀត មិនមែនគ្រប់កម្មវត្ថុទាំងអស់ដែលអាចមានប្រយោជន៍ គឺជាយុត្តិកម្មដែលអាចទទួលយកបានជាភាពចាំបាច់ផ្នែកយោធានោះឡើយ។ ឧទាហរណ៍ ការជម្លៀសដែលធ្វើឡើងដើម្បីការពារកងទ័ពពីការលុកលុយរបស់កងកម្លាំងសត្រូវ "ដ៏ច្រើនលើសលុប" អាចត្រូវបានផ្តល់យុត្តិកម្ម ប៉ុន្តែការជម្លៀសក្នុងគោលបំណងនៃ "ភាពចាំបាច់ផ្នែកយោធាក្នុងការការពារ ចារកម្ម និងដកហូតកម្លាំងប្រយុទ្ធរបស់សត្រូវ" មិនអាច ត្រូវបានផ្តល់យុត្តិកម្មឡើយ[104]។ ប្រភពមួយចំនួនបង្ហាញថា ការអះអាងដែលផ្អែកទៅលើភាពចាំបាច់ផ្នែកយោធាត្រូវតែសំដៅជាសំខាន់ ទៅលើសន្តិសុខរបស់ប្រជាជន និង ដូច្នេះហើយ "ការការពារភាពចាំបាច់ផ្នែកយោធាត្រូវបានកម្រិតត្រឹមស្ថានភាព ដែលមេបញ្ជាការកងទ័ពវិនិច្ឆ័យបានថា សុវត្ថិភាពរបស់ប្រជាជនស៊ីវិល តម្រូវឱ្យពួកគេត្រូវជម្លៀសចេញពីតំបន់ប្រយុទ្ធ និងមិនមែននៅពេលដែលមេបញ្ជាការកងទ័ពនេះ សម្រេចថានឹងអាចទទួលបានផលប្រយោជន៍ផ្នែកយោធា តាមរយៈការជម្លៀសប្រជាជនចេញ និងដុតកម្ទេចអ្វីៗគ្រប់យ៉ាងបន្ទាប់ពីពួកគេចាកចេញនោះឡើយ"[105]។ អង្គជំនុំជម្រះ ដោយពិចារណាលើការអះអាងអំពីភាពចាំបាច់ផ្នែកយោធា អាចពិចារណាផងដែរថាតើ មានភស្តុតាងណាមួយផ្សេងទៀតអំពីការរៀបចំឱ្យមានផលវិបាកផ្នែកយោធាជាអវិជ្ជមាន ដែរឬទេ ក្រៅពីការជម្លៀសប្រជាជនដែលបញ្ជាក់

---

[102] *Krstić,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៦៣, កថាខណ្ឌ ៥២៧។

[103] *Naletilic,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨០, កថាខណ្ឌ ៥២៦ (បានសម្រេចថាការជម្លៀសជាទង្វើខុសច្បាប់ ពីព្រោះប្រជាជនស៊ីវិលត្រូវបានឃាត់ទុកនៅក្នុងក្រុងមួយ ជាច្រើនថ្ងៃ មុនពេលជម្លៀសដែលទង្វើនេះបង្ហាញថា "ពុំមានមូលហេតុយោធាជាចាំបាច់ឡើយ")។

[104] *Krstić,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៦៣, កថាខណ្ឌ ៥២៦ (លុបចោលការទាញសំអាងខាងក្នុង)។

[105] de Zayas, *ការជម្លៀសប្រជាជនទ្រង់ទ្រាយធំ), ដូចខាងលើ* កំណត់សម្គាល់ ៤៨, ទំព័រ ២១៩។ សូមមើលផងដែរ Than & Shorts, *ដូចខាងលើ* កំណត់សម្គាល់ ៨០, ទំព័រ ១០០; *Blagojević និងអ្នកផ្សេងទៀត,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៨, កថាខណ្ឌ ៥៩៨។

អះអាងអំពីអំណះអំណាងនោះ[106]។

35. ភាពចាំបាច់ផ្នែកយោធាត្រូវបានកំណត់ដោយតុលាការយោធាសហរដ្ឋអាមេរិក Nuremberg នៅក្នុងការជំនុំជម្រះលើរឿងក្តី *Hostage*[107] នៅពេលដោះស្រាយលើអំណះអំណាងអំពីភាពចាំបាច់ផ្នែកយោធាជាការការពារតបតទៅនឹងការចោទប្រកាន់អំពីការរំលោភទៅលើអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩០៧ ដែលហាមឃាត់មិនឱ្យមានការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនស៊ីវិល។ ការកំណត់និយមន័យនេះគូសបញ្ជាក់អំពីការកម្រិតដែលអនុវត្តចំពោះភាពចាំបាច់ផ្នែកយោធា ទោះបីជានៅពេលដែលវាត្រូវបានយកមកអនុវត្តយ៉ាងត្រឹមត្រូវយ៉ាងណាក៏ដោយ ដោយបញ្ជាក់ថា ភាពចាំបាច់ផ្នែកយោធា នឹងមិនអនុញ្ញាតឱ្យមានការសម្លាប់ជនស៊ីវិលក្នុងគោលបំណង "សងសឹក ឬបំពេញនូវការល្អក់វង្វេងក្នុងការសម្លាប់មនុស្ស" និង/ឬ "បំផ្លិចបំផ្លាញ ទ្រព្យសម្បត្តិ នោះឡើយ"។ ភាពចាំបាច់ផ្នែកយោធា "មិនអនុញ្ញាតឱ្យមានការបំផ្លិចបំផ្លាញភូមិស្រុកយ៉ាងសាហាវ ឬធ្វើឱ្យអ្នកស្រុកទាំងនោះទទួលរងទុក្ខវេទនាដោយចេតនា សម្រាប់តែផលប្រយោជន៍ក្នុងការធ្វើឱ្យឈឺចាប់នោះឡើយ..."[108]។

36. តុលាការយោធាអង់គ្លេសនៅ Hamburg ក៏បានដោះស្រាយផងដែរលើការអះអាងអំពីភាពចាំបាច់ផ្នែកយោធានៅក្នុងរឿងក្តីពាក់ព័ន្ធនឹង *von Lewinski*[109] នៅក្នុងការការពារអំណះអំណាងអំពីការបំផ្លិចបំផ្លាញ

---

[106] សូមមើល "សវនាការលើរឿងក្តី Wilhelm List និងមនុស្សដទៃទៀត (សវនាការ Hostages)," នៅក្នុង *របាយការណ៍ច្បាប់ពាក់ព័ន្ធនឹងសវនាការឧក្រិដ្ឋជនសង្គ្រាមដែលត្រូវបានជ្រើសរើស និងរៀបចំឡើងដោយគណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ* (ភាគ VIII 1949)), ទំព័រ ៦៨ (ដោយកត់សម្គាល់ពីភស្តុតាងថា ការវាយប្រហារពីសូវៀតត្រូវបានស្មានទុកជាមុន)។

[107] *ដូចខាងលើ*, សូមមើលផងដែរ *Krstić*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៦៣, កថាខណ្ឌ ៥២៦ (លុបចោលការទាញសំអាងខាងក្នុង) (ពិភាក្សា និងប្រៀបធៀបសាលក្រមតុលាការ Hostages ជាមួយនឹងសាលក្រមរបស់ von Lewinski)។

[108] *សវនាការ Hostages*, សាលក្រម IMT, *ដូចខាងលើ* កំណត់សម្គាល់ ១១៣, ទំព័រ ៦៦។

[109] *នៅក្នុងរឿងក្តី re von Lewinski (ហៅ von Manstein)* (តុលាការយោធាអង់គ្លេស នៅ Hamburg, ប្រទេសអាល្លឺម៉ង់), ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៤៩, សេចក្តីសង្ខេប នៅក្នុង H. Lauterpacht, Q.C. (ed.), *កម្រងអត្ថបទសង្ខេប និងរបាយការណ៍ប្រចាំឆ្នាំស្តីពីរឿងក្តីនៃច្បាប់សាធារណៈអន្តរជាតិ, ឆ្នាំ១៩៤៩*, ទំព័រ ៥០៩; សូមមើលផងដែរ *Krstić*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៦៣, កថាខណ្ឌ ៥២៦។

ទ្រព្យសម្បត្តិ ដោយរំលោភទៅលើមាត្រា២៣(ឆ) នៃអនុសញ្ញាទីក្រុងឡាអេឆ្នាំ១៩០៧ ដែលបញ្ជាក់ថា "ការបំផ្លិចបំផ្លាញ ឬការរឹបអូសទ្រព្យសម្បត្តិរបស់សត្រូវ ត្រូវបានហាមឃាត់ លើកលែងតែការបំផ្លិចបំផ្លាញ ឬការរឹបអូសនោះគឺជាតម្រូវការចាំបាច់បំផុតផ្នែកសង្គ្រាម"។ នៅក្នុងការវាយតម្លៃអំពីការអះអាងនេះ តុលាការបានសង្កត់ធ្ងន់ថា ករណីលើកលែងនៃភាពចាំបាច់បំផុត គឺតិចតួចណាស់ ហើយមិនអនុញ្ញាតឱ្យមានការបំផ្លាញទ្រព្យសម្បត្តិឡើយ នៅពេលដែលវាគ្រាន់តែអាចមានផលប្រយោជន៍នោះពីព្រោះប្រការនេះនាំទៅដល់ការបំផ្លិចបំផ្លាញ[110]។

37. សេចក្តីអត្ថាធិប្បាយរបស់តុលាការ ICTR ទៅលើមាត្រា ៤៩ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV ឆ្លុះបញ្ចាំងនូវទស្សនៈនេះយ៉ាងច្បាស់៖ "ការជម្លៀសត្រូវបានអនុញ្ញាតតែ...នៅពេលដែលមានភាពសំខាន់ចាំបាច់បំផុតក្នុងការពិចារណាទៅលើផ្នែកយោធាប៉ុណ្ណោះ។ ប្រសិនបើពុំមានភាពចាំបាច់បំផុតនោះទេ ការជម្លៀសពុំត្រឹមត្រូវតាមច្បាប់ឡើយ"[111]។ សេចក្តីអត្ថាធិប្បាយនេះ ក៏បានបញ្ជាក់ផងដែរអំពីលក្ខណៈបណ្តោះអាសន្នចាំបាច់បំផុតនៃការជម្លៀស។ កាលៈទេសៈជាបទដ្ឋាននៃការជម្លៀសដែលស្របច្បាប់ គឺជា "ការជម្លៀសដែលពុំមានការរៀបចំទុកជាមុនដែលមានលក្ខណៈបណ្តោះអាសន្ន នៅពេលដែលមានភាពចាំបាច់បន្ទាន់ដើម្បីការពារប្រជាជនប្រកបដោយប្រសិទ្ធភាពប្រឆាំងនឹងគ្រោះថ្នាក់ដែលជិតមកដល់ និងមិនអាចដឹងជាមុនបាន"[112]។ ដូច្នេះ នៅពេលដែលមានការបង្ហាញថា សេចក្តីសម្រេចឱ្យមានការជម្លៀសត្រូវបានធ្វើឡើង

---

[110] *ដូចខាងលើ,* ទំព័រ ៥២២ ("ការដកកងទ័ព ដោយរក្សាទុកស្ថានភាពបំផ្លិចបំផ្លាញឱ្យនៅដដែល បានធ្វើឱ្យសត្រូវប្រឈមនឹងផលវិបាកជាក់ស្តែងជាច្រើន និងធ្វើឱ្យកងទ័ពដែលបានដកចេញមានផលប្រយោជន៍មួយចំនួន។ អង្គហេតុនេះតែមួយ មិនអាចចាត់ទុកជាយុត្តិកម្មបានទេ ប្រសិនបើគ្រាន់តែផ្អែកលើអត្ថន័យនៃពាក្យពេចន៍នៅក្នុងមាត្រានេះ។ ប្រសិនបើអង្គហេតុនេះអាចជាយុត្តិកម្មមែននោះ មាត្រានេះគ្មានន័យអ្វីឡើយ")។

[111] *បទអត្ថាធិប្បាយរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិលើអនុសញ្ញាទីក្រុងហ្សឺណែវលើកទី ៤), ដូចខាងលើ* កំណត់សម្គាល់ ១០, ទំព័រ ២៨០។ សូមមើលផងដែរ Nobuo Hayashi, *លក្ខខណ្ឌតម្រូវនៃភាពចាំបាច់ផ្នែកយោធានៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ),* ទិនានុប្បវត្តិច្បាប់អន្តរជាតិ លេខ ៣៩ នៃសាកលវិទ្យាល័យ Boston ២៨ (២០១០), ទំព័រ ៦៨ (ដែលបានធ្វើការកត់សម្គាល់លើពាក្យពេចន៍ផ្សេងៗ ដូចជា 'មិនអាចខ្វះបាន' 'ចំបាច់' 'លក្ខខណ្ឌតម្រូវ' 'សំខាន់' ។ល។ ត្រូវបានយកមកប្រើប្រាស់ដើម្បីគូសបញ្ជាក់ពីកាលៈទេសៈលើកលែងដែលតម្រូវឱ្យមានការជម្លៀស)។

[112] *បទអត្ថាធិប្បាយ ICRC ស្តីពីអនុសញ្ញាក្រុងហ្សឺណែវទីបួន, ដូចខាងលើ* កំណត់សម្គាល់ ១០, ទំព័រ ២៨១។

តាំងពីយូរមកហើយ មុនពេលមានការជម្លៀស ឬនៅមុនពេលកាលៈទេសៈចាំបាច់កើតឡើងនោះ ប្រការនេះនឹងបង្ហាញឲ្យឃើញថាការផ្លាស់ទីកន្លែង គឺជាលទ្ធផលនៃគោលនយោបាយ មិនមែនជាដំណោះស្រាយចាំបាច់ និងពិតប្រាកដចំពោះស្ថានការណ៍នោះទេ[113]។

38. លក្ខខណ្ឌតម្រូវបន្ថែមដែលមានសារៈសំខាន់ដើម្បីបង្កើត "ភាពចាំបាច់ផ្នែកយោធា" រួមមាន៖

i. វិធានការត្រូវបានធ្វើឡើងជាក់ស្តែងសម្រាប់សម្រេចគោលបំណងផ្នែកយោធាជាក់លាក់មួយចំនួន។

ii. វិធានការនោះត្រូវតែអនុវត្តជាចាំបាច់ សម្រាប់សម្រេចបាននូវគោលបំណងផ្នែកយោធា។

iii. គោលបំណងផ្នែកយោធាក្រោមវិធានការ ដែលត្រូវបានធ្វើឡើងនោះ ត្រូវអនុលោមតាមច្បាប់មនុស្សធម៌អន្តរជាតិ និង

iv. ម្យ៉ាងវិញទៀត វិធានការនោះត្រូវអនុលោមតាមច្បាប់មនុស្សធម៌អន្តរជាតិ[114]។

លក្ខខណ្ឌតម្រូវទាំងនេះគឺត្រួតគ្នា ដូច្នេះ "ប្រសិនបើវិធានការដែលធ្វើឡើងនោះ មិនបានបំពេញនូវលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងនោះទេ វិធានការនោះនឹងក្លាយជា "ភាពមិនចាំបាច់ផ្នែកយោធា" នៅក្នុងអត្ថន័យនៃខណលើកលែងនៃភាពចាំបាច់បំផុតផ្នែកយោធា"[115]។ លក្ខខណ្ឌតម្រូវនីមួយៗក្នុងចំណោមលក្ខខណ្ឌតម្រូវទាំងនេះ ចាំបាច់ត្រូវមានការពន្យល់បន្ថែមដោយសង្ខេប។

39. លក្ខខណ្ឌតម្រូវដែលថា វិធានការត្រូវធ្វើឡើងសម្រាប់គោលបំណងផ្នែកយោធាជាក់លាក់ តម្រូវឲ្យ "(i)

---

[113] *Krstić,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៦៣, កថាខណ្ឌ ៥២៦ (ដកស្រង់រឿងក្តី von Manstein) (ផែនការត្រូវបានកំណត់ជាមុន ហើយជនជាប់ចោទបានធ្វើផែនការដើម្បីអនុវត្ត បើទោះបីជាគ្មានការចាំបាច់ផ្នែកយោធាក៏ដោយ)។

[114] Hayashi, *ដូចខាងលើ* កំណត់សម្គាល់ ១១៨, ទំព័រ ៦២។

[115] *ដូចខាងលើ*

មានគោលបំណងជាក់លាក់ ពិតប្រាកដ ក្រោមវិធានការដែលត្រូវបានធ្វើឡើងនោះ និង (ii) គោលបំណងនេះមានលក្ខណៈផ្នែកយោធាជាចម្បង"[116]។ គោលបំណង "ផ្នែកយោធា" ត្រូវបានកំណត់លក្ខណៈតាមរយៈការគិតគូរដែលមានលក្ខណៈជាយុទ្ធសាស្ត្រ ប្រតិបត្តិការ ឬកលយុទ្ធ នៅក្នុងការរៀបចំផែនការត្រៀមរៀបចំ និងអនុវត្តសកម្មភាពប្រទូសរ៉ាយ"[117]។

40. ដោយផ្អែកជាចម្បងទៅលើការបកស្រាយអំពីយុត្តិសាស្ត្រ នៅសម័យសង្គ្រាមលោកលើកទីពីរថា ចំពោះវិធានការដែល "តម្រូវសម្រាប់ការសម្រេចបាននូវគោលបំណងផ្នែកយោធា" ត្រូវបង្ហាញថា៖

i. វិធានការនោះមានការពាក់ព័ន្ធជាក់ស្តែងសម្រាប់សម្រេចបាននូវគោលបំណងផ្នែកយោធា។

ii. ក្នុងចំណោមវិធានការពាក់ព័ន្ធជាក់ស្តែងនានា ដែលអាចយកមកអនុវត្តបានដោយសមហេតុផលនោះ វិធានការដែលត្រូវបានជ្រើសរើសនោះ គឺជាវិធានការដែលមានការខូចខាតតិចជាងគេបំផុត និង

iii. ការខូចខាតដែលកើតចេញមកពីការអនុវត្តវិធានការនេះ មិនវិសមាមាត្រទៅនឹងផលប្រយោជន៍ដែលនឹងទទួលបាន[118]។

វិធានការដែលត្រូវបានធ្វើឡើងនោះ មិនត្រឹមតែជាវិធានការតែមួយគត់ដែលអាចយកមកអនុវត្តបានដើម្បីសម្រេចបាននូវគោលបំណងផ្នែកយោធានោះទេ ប៉ុន្តែភាពចាំបាច់ផ្នែកយោធាក៏តម្រូវឲ្យវិធានការនោះត្រូវតែជា "វិធានការមួយដែលបង្កឲ្យមានការខូចខាតតិចបំផុតដល់សម្ភារៈ និងផលប្រយោជន៍នានាដែលត្រូវបានការពារដោយវិធានទាំងនេះ ទាក់ទិនទៅនឹងគោលបំណងផ្នែកយោធាដែលបានបញ្ជាក់ ភាពចាំបាច់បំផុតផ្នែកយោធាគឺមិនអាចទទួលយកបានឡើយ នៅពេលដែលអ្នកធ្វើសង្គ្រាមមិនបានអនុវត្ត យ៉ាងហោចណាស់នូវវិធានការពាក់ព័ន្ធជាក់ស្តែងណាមួយ

---

[116] *ដូចខាងលើ*, ទំព័រ ៦៣។

[117] *ដូចខាងលើ*, ទំព័រ ៦៤។

[118] *ដូចខាងលើ*, ទំព័រ ៦៩ (ពិនិត្យឡើងវិញលើសវនាការ *Peleus*, គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់ អសប, របាយការណ៍លើកទី១ច្បាប់ពីការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម ១ ដល់ ២១, ភាគ ១, ឆ្នាំ ១៩៤៧)។

ផ្សេងទៀតដែលមាន ហើយដែលបង្កការខូចខាតតិចតួចជាងវិធានការដែលត្រូវបានធ្វើឡើងដោយអ្នកធ្វើសង្គ្រាមនោះ”[119]។

41. អ្នកធ្វើអត្ថាធិប្បាយមួយរូបកត់សម្គាល់ថា “*ភាពចាំបាច់បំផុតផ្នែកយោធា* គឺមិនអាចទទួលយកបានឡើយ នៅពេលដែលគោលបំណងក្រោមវិធានការដែលត្រូវបានធ្វើឡើងនោះ ផ្ទុយទៅនឹងច្បាប់មនុស្សធម៌អន្តរជាតិ”[120]។ ទាក់ទិនទៅនឹងលក្ខខណ្ឌតម្រូវដែលថា វិធានការត្រូវអនុលោមតាមច្បាប់មនុស្សធម៌អន្តរជាតិ “នៅពេលដែលអ្នកធ្វើសង្គ្រាមត្រូវជ្រើសរើសរវាងវិធានការដែលពាក់ព័ន្ធនឹងគោលបំណងស្របច្បាប់របស់គាត់ ប៉ុន្តែជាអំពើខុសច្បាប់ និងវិធានការដែលឈានទៅដល់ការបោះបង់ចោលនូវគោលបំណងស្របច្បាប់នោះ ប៉ុន្តែពុំមែនជាអំពើខុសច្បាប់ *ភាពចាំបាច់បំផុតផ្នែកយោធា*នឹងតម្រូវឲ្យគាត់ជ្រើសយកវិធានការទីពីរ គឺវិធានការដែលឈានទៅដល់ការបោះបង់ចោលនូវគោលបំណងស្របច្បាប់នោះ ប៉ុន្តែពុំមែនជាអំពើខុសច្បាប់”[121]។

42. នៅក្នុងការវាយតម្លៃថាតើ ការអះអាងរបស់ជនជាប់ចោទថា គាត់បានប្រព្រឹត្តក្រោមយុត្តិកម្មមួយក្នុងចំណោមយុត្តិកម្មពីរដែលអាចទទួលយកបាន មានលក្ខណៈសមហេតុផល ឬយ៉ាងណានោះ តុលាការត្រូវតែវិភាគទៅលើស្ថានភាពដែលចេញពីទស្សនៈរបស់បុគ្គលនៅពេលដែលគាត់ បានអនុវត្តការជម្លៀសដោយបង្ខំ។ វាចាំបាច់តម្រូវឲ្យមានការវិភាគពីរផ្នែក គឺ*ការវិភាគអត្តនោម័ត/សត្យានុម័ត*៖ តុលាការត្រូវតែពិចារណាលើអង្គហេតុ ទៅតាមទស្សនៈអត្តនោម័តរបស់ជនជាប់ចោទនៅពេលនោះ ប៉ុន្តែបន្ទាប់មកត្រូវសម្រេច ថាតើអង្គហេតុទាំងនោះគាំទ្រជាសត្យានុម័តដល់ការបកស្រាយដ៏សមហេតុផលថា សន្តិសុខរបស់ប្រជាជនស៊ីវិល ឬភាពចាំបាច់បំផុតផ្នែកយោធា ផ្តល់យុត្តិកម្មចំពោះការជម្លៀសនោះ ឬយ៉ាង

---

[119] *ដូចខាងលើ,* ទំព័រ ៧២ ដល់ ៧៣។

[120] *ដូចខាងលើ,* ទំព័រ ៨៧។

[121] *ដូចខាងលើ,* ទំព័រ ៩២។

ណា[122]។ ដូចដែលបានពន្យល់នៅក្នុងសាលក្រមក្នុងរឿងក្តី Hostages "យើងត្រូវយកបារម្ភនឹងបញ្ហាថាតើចុងចោទនៅពេលមានព្រឹត្តការណ៍កើតឡើងនោះ បានប្រព្រឹត្តនៅក្នុងដែនកំណត់នៃការវិនិច្ឆ័យដ៏សុចរិតដោយផ្អែកលើមូលដ្ឋាននៃស្ថានភាពទូទៅនៅពេលនោះ ឬយ៉ាងណា"[123]។ តុលាការបានសម្រេចថា ទោះបីជាចុងក្រោយពុំមានភាពចាំបាច់បំផុតផ្នែកយោធាក៏ដោយ នៅពេលដែលស្ថានការណ៍ត្រូវបានវិនិច្ឆ័យថាជាលក្ខខណ្ឌដែលបានកើតឡើងចំពោះចុងចោទ នៅពេលនោះ ចុងចោទមិនមានការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ[124]។

43. តុលាការយោធាអង់គ្លេសនៅ Hamburg បានអនុវត្តវិធីសាស្ត្រដូចគ្នានេះនៅក្នុងការសម្រេចលើរឿងក្តីពាក់ព័ន្ធនឹង *von Lewinski* ដោយបញ្ជាក់ថា ក្នុងការកំណត់អំពីពិរុទ្ធភាព "លោកត្រូវវិនិច្ឆ័យ ថាតើជនជាប់ចោទ ដោយបានពិចារណាទៅលើតួនាទីដែលគាត់មាន និងស្ថានភាពទូទៅនៅពេលនោះ បានប្រព្រឹត្តដោយមានជំនឿដ៏សុចរិតថាអ្វី ដែលគាត់កំពុងធ្វើនោះគឺសមហេតុផលត្រឹមត្រូវតាមច្បាប់ ឬយ៉ាងណា"[125]។ នៅក្នុងការសម្រេចអំពីបញ្ហានេះ តុលាការត្រូវតែពិចារណាលើអង្គហេតុសត្យានុម័ត ដូចដែលឯកសារនេះបានលើកយកមកបង្ហាញ ព្រមទាំងទំហំដែលការបំផ្លិចបំផ្លាញនោះត្រូវបានធ្វើឡើង[126]។

44. លទ្ធផលចំពោះគោលការណ៍ដែលថា សេចក្តីសម្រេចត្រូវតែពិចារណាចេញពីទស្សនៈរបស់ជនជាប់ចោទ នៅពេលដែលគាត់បានធ្វើការសម្រេចចិត្តនោះ គឺថាជនជាប់ចោទក៏អាចមិនធ្វើការអះអាងអំពីភាពចាំបាច់ដោយផ្អែកលើការយល់ដឹងដែរ។ "ចម្លើយអះអាងអំពីភាពចាំបាច់បំផុតផ្នែកយោធា ត្រូវតែបានធ្វើការវាយតម្លៃដោយពិចារណាទៅលើគោលបំណង ដែលអ្នកធ្វើសង្គ្រាមមាននៅក្នុងចិត្ត នៅពេលដែលគាត់ជ្រើស

---

[122] *Krstić,* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY, *ដូចខាងលើ* កំណត់សម្គាល់ ៦៣, កថាខណ្ឌ ៥២៦ (ពិភាក្សាអំពីរឿងក្តី *Rendulic* ពីតុលាការយោធាសហរដ្ឋអាមេរិកនៅឯ Nuremberg ដែលតុលាការបានវាយតម្លៃពីភាពចាំបាច់ខាងយោធាដោយផ្អែកលើព័ត៌មានរបស់ជនជាប់ចោទនៅពេលនោះ)។

[123] *Hostages Trial,* សាលក្រមតុលាការយោធានអន្តរជាតិ, *ដូចខាងលើ* កំណត់សម្គាល់ ១១៣, ទំព័រ ៦៩។ សូមមើលផងដែរ Hayashi, *ដូចខាងលើ* កំណត់សម្គាល់ ១១៨, ទំព័រ ៩៦។

[124] *Hostages Trial*, សាលក្រមតុលាការយោធាអន្តរជាតិ, *ដូចខាងលើ* កំណត់សម្គាល់ ១១៣, ទំព័រ ៦៩។

[125] *von Manstein, ដូចខាងលើ* កំណត់សម្គាល់ ១០៩, ទំព័រ ៥២២ ដល់ ៥២៣។

[126] *ដូចខាងលើ។*

យកវិធានការនោះ។ អង្គហេតុតែមួយដែលវិធានការមួយគ្មានគោលដៅបានកើតឡើង ដើម្បីបំពេញគោលបំណងផ្នែកយោធា នៅពេលក្រោយមកទៀតនោះ មិនប្រែក្លាយវិធានការនោះ ជាប្រតិសកម្មឱ្យទៅជាភាពចាំបាច់បំផុតផ្នែកយោធាឡើយ[127]។

## IV. សំណូមពរ

សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ៖

ពិចារណាសារណានេះ ក្នុងការសម្រេចលើបទចោទក្នុងសំណុំរឿង០០២/០១។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ | លោកស្រី ជា លាង<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | លោក Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |

[127] Hayashi, *ដូចខាងលើ* កំណត់សម្គាល់ ១១១, ទំព័រ ៩៤, ទំព័រ ៩៧។